# សេចក្តីអត្ថាធិប្បាយរបស់អង្គការសហប្រជាជាតិ

# គោលការណ៍ណែនាំ

# ស្តីពី

# ការបណ្តេញចេញ និង ការតាំងទីលំនៅថ្មី

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

# សេចក្តីអត្ថាធិប្បាយរបស់អង្គការសហប្រជាជាតិ

# គោលការណ៍ណែនាំ

# ស្តីពី

# ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី

បោះពុម្ពឡើងវិញ ខែមិថុនា ២០១៣

កូនសៀវភៅនេះ គឺជាការបោះពុម្ពផ្សាយដោយ
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ
ទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំនៅកម្ពុជា


**អង្គការសហប្រជាជាតិ**
**សិទ្ធិមនុស្ស**
**ការិយាល័យឧត្តមស្នងការ**

***កម្ពុជា***

# មាតិកា

**១- សេចក្តីអត្ថាធិប្បាយរបស់អង្គការសហប្រជាជាតិ និង គោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មី**

អារម្ភកថា.......................................................................................៧

សំណួរដែលត្រូវបានសួរជាញឹកញាប់...................................................១១

**២- សេចក្តីពន្យល់រួម លេខ៧ ស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ ការបណ្តេញចេញដោយបំពាន ..........................................................................................................១៩**

**៣- គោលការណ៍ជាមូលដ្ឋាន និង គោលការណ៍ណែនាំ ស្តីពី ការបណ្តេញចេញ និងការចាកចេញដោយបង្ខំចិត្ត ផ្អែកលើការអភិវឌ្ឍន៍ ........................................... ៣៧**

I- វិសាលភាព និង ចរិតលក្ខណៈ ............................................................ ៣៧

II- កាតព្វកិច្ចទូទៅ ......................................................................................៤៣

ក. អ្នកបំពេញកាតព្វកិច្ច និងចរិតនៃកាតព្វកិច្ច ....................................៤៣

ខ. គោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន ................................................៤៤

គ. ការអនុវត្តន៍កាតព្វកិច្ចរដ្ឋ ....................................................................៤៦

ឃ. យុទ្ធសាស្ត្រ គោលនយោបាយ និង កម្មវិធីបង្ការ ..............................៥០

III- នៅមុនពេលបណ្តេញចេញ ....................................................................៥៣

IV- នៅក្នុងពេលបណ្តេញចេញ ....................................................................៥៦

V- បន្ទាប់ពីការបណ្តេញចេញៈ ជំនួយបន្ទាន់ និងការតាំងទីលំនៅថ្មី ..............៥៨

VI- ការដោះស្រាយសំរាប់ការបណ្តេញចេញដោយបំពាន ............................៦៤

ក. សំណង ........................................................................................................៦៥

ខ. បដិទាន (ការសងវិញ) និងការអោយវិលត្រឡប់មកវិញ ...................៦៧

គ. ការតាំងទីលំនៅថ្មី និងការស្តារនីតិសម្បទា..................................៦៩
VII- ការឃ្លាំមើល ការវាយតំលៃ និងការតាមដានការអនុវត្តន៍ ..................៧០
VIII- តួនាទីរបស់សហគមន៍អន្តរជាតិ រួមទាំង អង្គការអន្តរជាតិនានា ........៧០
IX. ការបកស្រាយគោលការណ៍ ................................................................៧១

# សេចក្ដីអត្ថាធិប្បាយរបស់អង្គការសហប្រជាជាតិ និង គោលការណ៍ណែនាំ ស្ដីពី

# ការបណ្ដេញចេញ និងការតាំងទីលំនៅថ្មី

## អារម្ភកថា

ដំណើរការនៃការបណ្ដេញចេញ និងការតាំងទីលំនៅថ្មី បានក្លាយជាកង្វល់ខ្លាំងនៅកម្ពុជា ដែលមានផលវិបាកធ្ងន់ធ្ងរដល់ការរស់នៅ និងសុខមាលភាពបុគ្គល និងសហគមន៍ផ្សេងៗ។ កូនសៀវភៅនេះ មានបញ្ចូលឯកសារសំខាន់ៗចំនួនពីររបស់អង្គការសហប្រជាជាតិ ដែលដោះស្រាយជាក់លាក់ចំពោះបញ្ហាទាំងនេះ ៖

– **សេចក្ដីពន្យល់រួម លេខ ៧ ស្ដីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ (មាត្រា១១ (១) នៃកតិកាសញ្ញានេះ)៖ ការបណ្ដេញចេញដោយបំពាន** ដែលបានរៀបរៀងឡើងដោយ គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

– **គោលការណ៍ជាមូលដ្ឋាន និង គោលការណ៍ណែនាំស្ដីពីការបណ្ដេញចេញ និងការចាកចេញដោយបង្ខំ ផ្អែកលើការអភិវឌ្ឍន៍** (ចាប់ពីនេះទៅហៅថា "គោលការណ៍ណែនាំ" ដែលបានរៀបរៀងដោយអ្នករាយការណ៍ពិសេសស្ដីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ។

សេចក្ដីពន្យល់រួមលេខ៧ និងគោលការណ៍ណែនាំ បរិយាយលំអិតអំពីការហាមប្រាមនៃ "ការបណ្ដេញចេញដោយបំពាន" កំនត់ពីការធានាការពារខាងនីតិវិធី ដែលបានតម្រូវឲ្យមាន ក្នុងពេល

អនុវត្តការបណ្តេញចេញ និងរៀបរាប់អំពីបទដ្ឋានអប្បបរមា ក្នុងការអនុវត្តដំណើរការឲ្យចាកចេញដោយបង្ខំចិត្ត និងការតាំងទីលំនៅថ្មី។

គណៈកម្មាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (CESCR) ឃ្លាំមើលការអនុវត្តន៍កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR)។ គណៈកម្មាធិការនេះ ចេញនូវ "សេចក្តីពន្យល់រួម" ដើម្បីបញ្ជាក់ ឬពន្យល់អំពីបទប្បញ្ញត្តិជាក់លាក់មួយចំនួននៃកតិកាសញ្ញានេះ។ ក្នុងបរិបទនេះ នៅក្នុងឆ្នាំ១៩៩៧ គណៈកម្មាធិការ CESCR បានចេញសេចក្តីពន្យល់រួម លេខ ៧ ស្តីពីការបណ្តេញចេញដោយបំពាន ដូចការបកស្រាយនៃមាត្រា១១ (១) នៃ កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ( ICESCR ) ចែងអំពីសិទ្ធិមានលំនៅដ្ឋានសមរម្យ។

គោលការណ៍ណែនាំនេះ ត្រូវបានបង្កើតឡើង ដើម្បីជួយរដ្ឋនានា និងសហគមន៍អន្តរជាតិ ក្នុងការបង្កើតគោលនយោបាយ និងផែនការផ្សេងៗ ដើម្បីដោះស្រាយការបណ្តេញដោយបំពាន។ គោលការណ៍ណែនាំទាំងនេះ ផ្តល់សេចក្តីណែនាំបន្ថែម ផ្អែកលើការពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធ និងបទពិសោធន៍ដែលទទួលបាននៅជុំវិញពិភពលោក ចាប់តាំងពីសេចក្តីពន្យល់រួម លេខ ៧ ត្រូវបានដាក់ចេញ។ អ្នករាយការណ៍ពិសេស ស្តីពីសិទ្ធិមានលំនៅដ្ឋាន

សមរម្យ[១] បានបង្ហាញគោលការណ៍ណែនាំនេះជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នាទីក្រុងហ្សឺណែវ ក្នុងឆ្នាំ២០០៧ ជាផ្នែកមួយ នៃអាណត្តិរបស់គាត់ ដែលគោលការណ៍នេះបានបង្ហាញពីវិធីសាស្ត្រផ្សេងៗ សំរាប់អនុវត្តឲ្យបានប្រសើរឡើងថែមទៀតនូវសិទ្ធិមានលំនៅដ្ឋានសមរម្យ។

ខណៈដែលសេចក្តីពន្យល់រួម លេខ៧ ពិភាក្សាអំពីការបណ្តេញចេញដោយបំពាន ជាទូទៅគោលការណ៍ណែនាំ និយាយជាក់លាក់អំពីភាពជាប់ជំពាក់ខាងសិទ្ធិមនុស្សនៃការបណ្តេញចេញ និង ការចាកចេញដោយបង្ខំចិត្តផ្អែកលើ*ការអភិវឌ្ឍន៍*។ គោលការណ៍ណែនាំទាំងនេះ គឺជាឧបករណ៍ប្រតិបត្តិការមួយបង្ហាញអំពី "ជំហ៊ានមួយទៅជំហ៊ានមួយ" ពីរបៀបដែលត្រូវធានាការពារសិទ្ធិមនុស្ស នៅមុនពេល នៅក្នុងពេល និងនៅក្រោយពេលការចាកចេញដោយបង្ខំចិត្ត។ គេអាចប្រើគោលការណ៍ណែនាំទាំងនេះ ដើម្បីដោះស្រាយបញ្ហាប្រឈមទូទៅ ដែលកើតមានក្នុងគំរោងអភិវឌ្ឍន៍ផ្សេងៗ ទោះជាក្នុងការរៀបចំសោភ័ណ្ឌភាពទីក្រុង ឬហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយធំក្តី។

[១] តំណែងផ្លូវការរបស់អ្នករាយការណ៍ពិសេសនេះគឺ "អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ ជាផ្នែកមួយនៃសិទ្ធិមានកំរិត ជីវភាព សមរម្យ និងសិទ្ធិគ្មានការរើសអើងក្នុងបរិបទនេះ" ។ អាណត្តិរបស់អ្នករាយការណ៍ពិសេសនេះ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០០។ អ្នករាយការណ៍ពិសេស ត្រូវបានប្រគល់អាណត្តិ ដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដើម្បីពិនិត្យ ផ្តល់យោបល់ និងរាយការណ៍អំពីស្ថានភាពសិទ្ធិមនុស្ស ឬការរំលោភសិទ្ធិមនុស្សនៅទូទាំងពិភពលោក។

ការិយាល័យ OHCHR នឹងបោះពុម្ពផ្សាយឯកសារសំខាន់ៗទាំងពីរនេះ ដោយរួមបញ្ចូលគ្នានៅក្នុងកូនសៀវភៅមួយ ដោយសង្ឃឹមថា ឯកសារទាំងនេះនឹងជួយដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងដៃគូពាក់ព័ន្ធឯទៀត ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើនិយតកម្មដល់ដំណើរការនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មី ដើម្បីជាប្រយោជន៍ដល់មនុស្សគ្រប់រូបនៅប្រទេសកម្ពុជា។

*ការិយាល័យ OHCHR ប្រចាំនៅកម្ពុជា ខែធ្នូ ឆ្នាំ២០០៩*

# សំណួរដែលត្រូវបានសួរជាញឹកញាប់

## តើសិទ្ធិមានលំនៅដ្ឋានសមរម្យជាអ្វី ?

ទន្ទឹមនឹងមានប្រជាជនពិភពលោកភាគច្រើន រស់នៅក្នុងទម្រង់ជាផ្ទះសម្បែងតាមតំបន់ក្រីក្រតាមទីប្រជុំជន ក៏មានប្រជាជនរាប់លាននាក់ រស់នៅក្នុងស្ថានភាពដែលគំរាមកំហែងដល់ អាយុជីវិត ឬសុខភាព ក្នុងតំបន់ក្រីក្រតាមទីប្រជុំជន ឬតាមតំបន់រស់នៅមិនទាន់រៀបរយ និងមិនទទួលបានសិទ្ធិខាងលំនៅដ្ឋាន "សមរម្យ" ពិតប្រាកដ។ សហគមន៍អន្តរជាតិ បានទទួលស្គាល់ថា លំនៅដ្ឋានមិនសំដៅត្រឹមតែរចនាសម្ព័ន្ធរូបវន្ត ដែលមានតែតួ ដំបូល និងជញ្ជាំងប៉ុណ្ណោះទេ ប៉ុន្តែវាមានទស្សនទានទូទៅច្រើនជាងនោះ ដែលរាប់ទាំងសម្ភារៈ សំណង់ និងវត្ថុធាតុផ្សេងទៀត ដែលមិនមែនជាសម្ភារៈសំណង់ ដែលសំខាន់ចាំបាច់ដើម្បីបង្កើតបានជាកន្លែងរស់នៅមួយគត់មត់ និងមានសុវត្ថិភាព។

រដ្ឋាភិបាលនានា បានទទួលស្គាល់ថា លំនៅដ្ឋានសមរម្យ គឺជា*សិទ្ធិមួយ* ដែលវាមិនគ្រាន់តែជាទិសដៅរយៈពេលវែងមួយប៉ុណ្ណោះទេ។ សិទ្ធិមានលំនៅដ្ឋានសមរម្យ គឺជាសមាសធាតុរួមមួយនៃសិទ្ធិមានកំរិតជីវភាពរស់នៅសមរម្យ ដែលត្រូវបានគេទទួលស្គាល់នៅដើមឆ្នាំ១៩៤៨ ក្នុងមាត្រា២៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងបន្ទាប់មកទៀត ក្នុងមាត្រា១១ (១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR)។

សិទ្ធិមានលំនៅដ្ឋានសមរម្យ អាចឲ្យនិយមន័យថា "សិទ្ធិស្រ្តីបុរស យុវជន និងកុមារគ្រប់រូប ក្នុងការទទួលបាន និងរក្សាផ្ទះសម្បែងមួយគត់មត់ ហើយសហគមន៍ដែលពួកគេរស់នៅមានភាព

សុខដុមរម្យនា និងសេចក្តីថ្លៃថ្នូរ។[2]

សិទ្ធិមានលំនៅដ្ឋានសមរម្យ មានន័យទូលាយជាងសិទ្ធិធ្វើជាម្ចាស់ទ្រព្យសម្បត្តិ ដោយសារសិទ្ធិនេះ សំដៅធានាអោយ*មនុស្សគ្រប់រូប* មានកន្លែងរស់នៅសុខសាន្ត និងមានសេចក្តីថ្លៃថ្នូរ រាប់ទាំងអ្នកដែលមិនមែនជាម្ចាស់ទ្រព្យផងដែរ។ សិទ្ធិមានលំនៅដ្ឋានសមរម្យ រាប់បញ្ចូលផងដែរនូវការការពារប្រឆាំងនឹងការបណ្តេញចេញដោយបំពាន ការបំផ្លិចបំផ្លាញ និងការវាយកំទេចផ្ទះសម្បែងរបស់បុគ្គលណាមួយតាមទំនើងចិត្ត។

## តើសិទ្ធិមានលំនៅដ្ឋានសមរម្យ និងការការពារប្រឆាំងនឹងការបណ្តេញចេញបានឆ្លុះបញ្ចាំងយ៉ាងដូចម្តេចក្នុងច្បាប់កម្ពុជា ?

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (RGC) បានផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR) ដែលរាប់ទាំងសិទ្ធិមានលំនៅដ្ឋានសមរម្យ។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ធានាការពារសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលមានកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR) ផងដែរ ដែលជាផ្នែកមួយនៃច្បាប់ជាតិរបស់ប្រទេសកម្ពុជា។

មាត្រា៤៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់សិទ្ធិជាម្ចាស់ទ្រព្យ និងចែងអំពីការដកហូត ដើម្បីជាប្រយោជន៍សាធារណៈ។ ច្បាប់ភូមិបាល ឆ្នាំ២០០១ ទទួលស្គាល់ដូចគ្នានេះដែរ អំពីសិទ្ធិកម្មសិទ្ធិលើអចលនទ្រព្យ (ផ្ទះសម្បែង ឬដីធ្លី) និងបញ្ចូល

[2] UN Special Rapporteur on adequate housing, E/CN.4/2001/51, para. 8

ប្បញ្ញត្តិស្តីពីការដកហូតទ្រព្យសម្បត្តិ (អស្សាមិករណ៍) ។

រដ្ឋធម្មនុញ្ញ ក៏ទទួលស្គាល់កាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធានាការពារសិទ្ធិស្ត្រី និងកុមារ សិទ្ធិខាងអប់រំ និងសុខភាព និងក្នុងការចាត់វិធានការជាច្រើនខាងសង្គម ដើម្បីលើកកំពស់សុខមាលភាពប្រជាពលរដ្ឋកម្ពុជា។ កាតព្វកិច្ចទាំងនេះពាក់ព័ន្ធខ្លាំងដល់ដំណើរការតាំងទីលំនៅថ្មី។

នៅពេលកំពុងសរសេរអត្ថបទនេះ នៅមិនទាន់មានច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធណា មួយត្រូវបានអនុម័ត ដើម្បីហាមប្រាមជាក់លាក់ចំពោះការបណ្តេញចេញដោយបំពាន ឬធ្វើនិយតកម្មដំណើរការនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅឡើយទេ។

## តើ "ការបណ្តេញចេញ" និង "ការបណ្តេញចេញដោយបំពាន" មានអ្វីខុសប្លែកគ្នាខ្លះ?

ការបណ្តេញចេញ គឺជាការឲ្យអ្នកណាម្នាក់ចាកចេញពីផ្ទះសម្បែងឬដីធ្លីរបស់ខ្លួនដោយដំណើរការតាមផ្លូវច្បាប់។ ការបណ្តេញចេញ ក្នុងពាក្យពេចន៍របស់វា មិនមែនជាការរំលោភសិទ្ធិមនុស្សទេ ដោយសារវាអាចមានហេតុផលផ្លូវច្បាប់ ដែលចាំបាច់ត្រូវឲ្យមានការបណ្តេញចេញ។ ឧទាហរណ៍ នៅពេលអ្នកណាម្នាក់មិនបង់ថ្លៃឈ្នួលផ្ទះ ម្ចាស់ផ្ទះអាចសុំឲ្យតុលាការចេញសេចក្តីបង្គាប់ឲ្យធ្វើការដកហូតទ្រព្យសម្បត្តិពីបុគ្គលនោះមកវិញបាន។

ទោះជាយ៉ាងណាក៏ដោយ ក្នុងទស្សនទាននៃភាពសំខាន់ជាសារវន្តនៃមនុស្សជាតិ ក្នុងការមានលំនៅដ្ឋានសមរម្យ និងកំរិតសុវត្ថិភាពក្នុងការកាន់កាប់ ការបណ្តេញចេញ ត្រូវតែជាមធ្យោបាយចុង

ក្រោយបំផុត និង ត្រូវស្ថិតក្នុងកាលៈទេសៈពិសេសតែប៉ុណ្ណោះ។ ការងារនេះ ត្រូវតែគ្រប់គ្រង និងធ្វើដោយប្រយ័ត្នប្រយែងបំផុត ដោយអនុលោមទៅតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

ប្រសិនជាការធានាការពារតាមផ្លូវច្បាប់ និងនីតិវិធី មិនត្រូវបានគេគោរពទេ នោះការបណ្តេញ គឺជាទង្វើមួយខុសច្បាប់ ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ហើយត្រូវចាត់ទុកថាជា "**ការបណ្តេញចេញដោយបំពាន**" ។ ការបណ្តេញចេញដោយបំពាន មានធាតុផ្សំដូចជា៖ ការធ្វើតាមទំនើងចិត្ត អនីត្យានុកូលភាព ការមិនស្មុគ្រចិត្ត និងការធ្វើអោយមនុស្សទទួលរងការឈឺចាប់ច្រើនហួសហេតុ។

សំរាប់និយមន័យទូលាយជាងនេះនៃការបណ្តេញចេញ និងការការបណ្តេញចេញដោយបំពាន សូមមើលសេចក្តីពន្យល់រួមលេខ ៧ និងគោលការណ៍ណែនាំនេះ។

## តើត្រូវធានាការពារអ្វីខ្លះ នៅក្នុងពេលធ្វើការបណ្តេញចេញ?

អាជ្ញាធរ ត្រូវគោរពយ៉ាងម៉ឺងម៉ាត់នូវកិច្ចការពារផ្លូវច្បាប់ និងនីតិវិធី ដើម្បីធានាឲ្យការបណ្តេញចេញធ្វើឡើងដោយមិនមានការរំលោភសិទ្ធិជនដែលរងផលប៉ះពាល់ និងគោរពតាមគោលការណ៍ស្តីពី នីតិវិធីត្រឹមត្រូវ ភាពសមហេតុសមផល និងភាពសមាមាត្រ។ ការធានាការពារទាំងនេះ រាប់ទាំងការផ្តល់ឱកាសសំរាប់ការពិគ្រោះយោបល់ពិតប្រាកដ បញ្ចៀសការប្រើប្រាស់កំលាំងមិនសមាមាត្រ ការជូនដំណឹងគ្រប់គ្រាន់ និងសមហេតុផល និងការផ្តល់ឲ្យមានការដោះស្រាយសំណងតាមផ្លូវច្បាប់។ បញ្ជីស្តីពីការធានាការពារច្រើនទៀត មានរៀបរាប់ក្នុងសេចក្តីពន្យល់រួមលេខ ៧ ត្រង់កថាខ័ណ្ឌទី ១៥។

ម្យ៉ាងវិញទៀត **លទ្ធផលនៃការបណ្តេញចេញ** មិនត្រូវនាំពួកគេក្លាយជាមនុស្សគ្មានផ្ទះសម្បែង ឬធ្លាក់ក្នុងស្ថានភាពលំបាកធ្ងន់ធ្ងរឡើយ។ គោលការណ៍ណែនាំនេះ (ផ្នែកទីV) គូសបញ្ជាក់ពីលក្ខខណ្ឌអប្បបរមា ដែលត្រូវតែធានាឲ្យមាននៅទីកន្លែងតាំងទីលំនៅថ្មី ដូចជា ការមានលំនៅដ្ឋានសមរម្យ ចំណីអាហារ ទឹក និងអនាម័យចាំបាច់ ការទទួលបានកិច្ចគាំពារសុខភាព និងសេវាផ្សេងៗទៀតដូចជា ឱកាសចិញ្ចឹមជីវិត និងការអប់រំ។

## តើការបណ្តេញចេញ ការចាកចេញដោយបង្ខំចិត្ត និងការតាំងទីលំនៅថ្មី មានលក្ខណៈខុសប្លែកគ្នាយ៉ាងដូចម្តេច?

**ការបណ្តេញចេញ** គឺជាអំពើ ឬសកម្មភាពដែលបុគ្គល ក្រុម ឬស្ថាប័ន ដែលជារឿយៗគឺរដ្ឋាភិបាលជាអ្នកអនុវត្តការងារនេះ ដើម្បីបង្ខំប្រជាជនឲ្យចាកចេញពីផ្ទះសម្បែង ឬដីធ្លីរបស់ខ្លួន។

**ការចាកចេញដោយបង្ខំចិត្ត** កើតឡើងនៅពេលដែលប្រជាជនត្រូវគេចខ្លួន ឬចាកចេញពីផ្ទះសម្បែង ដីធ្លី ឬនិវេសនដ្ឋានរបស់ខ្លួន។ ការចាកចេញដោយបង្ខំចិត្ត អាចបណ្តាលពីមូលហេតុធម្មជាតិ ឬមនុស្សជាអ្នកបង្កឡើង។ ការចាកចេញដោយបង្ខំចិត្ត កើតឡើងដោយសារ ឬដើម្បីគេចខ្លួនចេញពីស្ថានភាពមួយចំនួន ដូចជា៖ ជម្លោះប្រដាប់អាវុធ អំពើហិង្សាទូទៅ ការរំលោភសិទ្ធិមនុស្ស គ្រោះមហន្តរាយដោយធម្មជាតិ ឬដោយមនុស្សជាអ្នកបង្កឡើង និង/ឬដោយគម្រោងអភិវឌ្ឍន៍ផ្សេងៗ។

**ការតាំងទីលំនៅថ្មី** គឺជាសកម្មភាពនៃការរុះរើពីកន្លែង ឬផ្ទះមួយទៅទីតាំងជាក់លាក់ណាមួយ។ ការតាំងទីលំនៅថ្មី មិនចាំបាច់ទាល់តែត្រូវគេបង្ខំនោះទេ ពេលខ្លះមនុស្សអាចសម្រេចចិត្តរុះរើទៅ

កាន់ទីលំនៅថ្មីដោយខ្លួនឯង។ ផ្ទុយទៅវិញ ការបណ្តេញចេញ និង ការចាកចេញដោយបង្ខំចិត្ត គឺមិនមានការស្ម័គ្រចិត្តនោះទេ។

## តើពាក្យទាំងនេះ មានលក្ខណៈប្រហាក់ប្រហែលគ្នាទេ ជាភាសាខ្មែរ?

ពាក្យថា "eviction" ជាភាសាខ្មែរ ជាទូទៅត្រូវបានបកប្រែថា "ការបណ្តេញចេញ" ដែលមកពី កិរិយាស័ព្ទ "បណ្តេញចេញ" មានន័យថា "ដេញអ្នកណាម្នាក់ចេញ" ។ ជារឿយៗ គេយល់ថា ពាក្យនេះមានទស្សនទានអវិជ្ជមាន ដែលមិនស្របទៅតាមន័យ "eviction" ជាភាសាអង់គ្លេសឡើយ ដោយសារ ថាដំណើរការបណ្តេញចេញ បើទោះជាធ្វើទៅតាមផ្លូវច្បាប់ ឬមានបញ្ជាក់ហេតុផលត្រឹមត្រូវក្តី ក៏ជារឿយៗដំណើរការនេះ នាំឲ្យមានការទទួលរងការឈឺចាប់។

មនុស្សដែលជំទាស់នឹងទស្សនៈ អវិជ្ជមាននៃពាក្យ *"បណ្តេញចេញ"* បានតស៊ូមតិឲ្យ*ប្រើពាក្យ "ការតាំងទីលំនៅថ្មី"* ជំនួសវិញដែលបើតាមពាក្យមួយម៉ាត់ៗ វាមានន័យថា *"ការទៅរស់នៅកន្លែងថ្មី"* ។ ពាក្យនេះ បើបកប្រែជាភាសាអង់គ្លេសគឺ 'resettlement'។ ការតាំងទីលំនៅថ្មី អាចកើតមានបន្ទាប់ការបណ្តេញចេញ ប៉ុន្តែវាមិនមែនសុទ្ធតែដូច្នោះទេ។ ដូច្នេះ ពាក្យថា *"ការតាំងទីលំនៅថ្មី"* មិនបាននិយាយអោយបានក្បោះក្បាយអំពីដំណើរការ ដែលក្នុងនោះមានមនុស្សត្រូវគេបង្ខំឲ្យចាកចេញពីលំនៅដ្ឋានរបស់ខ្លួននោះឡើយ។

លក្ខណៈខុសគ្នារវាង 'resettlement' និង 'displacement' គឺ displacement ត្រូវបានបកប្រែថា "ការចាកចេញដោយបង្ខំចិត្ត" សំដៅដល់ការរើចាកចេញពីកន្លែងមួយ ដោយផ្ទុយទៅនឹងឆន្ទៈរបស់ខ្លួន។

មិនមានការបកប្រែផ្លូវការជាភាសាខ្មែរនៃពាក្យ '*forced* eviction'

ទេ។ គណៈកម្មាធិការស្ដីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (CESCR) ខ្លួនឯងផ្ទាល់ បានពិភាក្សាថា `*forced* eviction´ ជាភាសាអង់គ្លេស មិនចាំបាច់ទាល់តែមានជាប់ជំពាក់នឹងច្បាប់ទេ ប៉ុន្ដែវាជាការញែកឲ្យដាច់ពីការបណ្ដេញចេញទាំងឡាយណា ដែលអាចមានធម្មានុរូបភាព ក្រោមច្បាប់អន្ដរជាតិ។ សំរាប់គោលបំណងនៃការបោះពុម្ព ពាក្យថា ‵forced eviction´ ត្រូវបានប្រើសំដៅដល់ពាក្យ "បណ្ដេញចេញដោយបំពាន" ដែលសំដៅដល់ការបណ្ដេញចេញ ដែលរំលោភលើសេចក្ដីថ្លៃថ្នូរជាមនុស្សជាតិ ហើយមិនគិតគូរអំពីកាតព្វកិច្ចផ្លូវច្បាប់ឡើយ។

******

# សេចក្ដីពន្យល់រួមលេខ ៧
# ស្ដីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ
# ការបណ្ដេញចេញដោយបំពាន

## មាត្រា ១១ (១) ដោយគណៈកម្មាធិការស្ដីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## អនុម័តនៅថ្ងៃទី ២០ខែ ឧសភា ឆ្នាំ១៩៩៧

១- នៅក្នុងសេចក្ដីពន្យល់រួម លេខ៤ (១៩៩១) គណៈកម្មាធិការបានសង្កេតឃើញថា មនុស្សគ្រប់រូបគួរមានសន្តិសុខនៃការកាន់កាប់ដីធ្លីក្នុងកម្រិតមួយ ដែលធានាបាននូវការការពារតាមច្បាប់ មិនឱ្យមានការបណ្ដេញចេញដោយបំពាន ការយាយី និងការគំរាមកំហែងផ្សេងៗទៀត។ សេចក្ដីពន្យល់រួមនោះ បានសង្ខេបថា ការបណ្ដេញចេញដោយបំពាន *ពិតជា* ផ្ទុយនឹងលក្ខខណ្ឌបញ្ញត្តិនៃកតិកាសញ្ញា។ ដោយបានពិចារណាលើរបាយការណ៍សំខាន់ៗជាច្រើន ស្ដីពីការបណ្ដេញចេញដោយបំពាន ដែលបានកើតឡើងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ រួមទាំងព្រឹត្តិការណ៍ដែលខ្លួនបានកំណត់ថា ជាព្រឹត្តិការណ៍ដែលរំលោភលើកាតព្វកិច្ចរបស់រដ្ឋភាគីផង គណៈកម្មាធិការមានជំហរព្យាយាមពន្យល់បន្ថែមទៀត ទៅតាមលក្ខខ័ណ្ឌនៃកាតព្វកិច្ចដែលបានចែងនៅក្នុងកតិកាសញ្ញា។

២- សហគមន៍អន្តរជាតិ បានទទួលស្គាល់ជាយូរមកហើយថា បញ្ហានៃការបណ្តេញចេញដោយបំពាន គឺជា បញ្ហាយ៉ាងធ្ងន់ធ្ងរ ។ នៅឆ្នាំ១៩៧៦ នៅក្នុង *សន្និសីទរបស់អង្គការសហប្រជាជាតិ ស្តីពីការតាំងទីលំនៅដ្ឋានរបស់មនុស្សជាតិ* បានកត់សម្គាល់ថា រដ្ឋភាគីត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះ "ការអនុវត្តសកម្មភាពបណ្តេញចេញក្នុងទ្រង់ទ្រាយធំៗ គួរប្រព្រឹត្តទៅតែក្នុងករណីដែលការអភិរក្ស (ការរក្សាទុក) និង ការស្តារនីតិសម្បទានមិនអាចធ្វើទៅបាន និងវិធានការរៀបចំតាំងទីលំនៅដ្ឋានថ្មីត្រូវបានរៀបចំរួចជាស្រេច"i ។ នៅឆ្នាំ១៩៨៨ នៅក្នុងយុទ្ធសាស្ត្រពិភពលោក ស្តីពីទីជម្រកឆ្នាំ២000 ដែលអនុម័តដោយមហាសន្និបាត នៅក្នុងសេចក្តីសម្រេចចិត្តរបស់ខ្លួនលេខ៤៣/១៨១ ទទួលស្គាល់ថា "កាតព្វកិច្ចយ៉ាងសំខាន់ [របស់រដ្ឋាភិបាល] គឺការពារ និងកែលំអលំនៅដ្ឋាន និងភូមិដ្ឋាន មិនមែនបំផ្លាញ ឬកំទេចនោះទេ"ii ។ *របៀបវារៈ ២១* បានបញ្ជាក់ថា "ប្រជាជន ត្រូវការពារដោយច្បាប់ មិនឱ្យមានការបណ្តេញពួកគាត់ចេញពីលំនៅដ្ឋាន

---

i-របាយការណ៍របស់ Habitat: សន្និសីទអង្គការសហប្រជាជាតិ ស្តីពីលំនៅដ្ឋានមនុស្សជាតិ, នៅក្រុងវ៉ាន់ខូវើ, ថ្ងៃទី៣១ ខែឧសភា រហូតដល់ថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៦ (A/CONF.70/15). ជំពូក ២, អនុសាសន៍ B.8. កថាខ័ណ្ឌ C ចំណុច២ ។ (Report of Habitat: United Nations Conference on Human Settlements, Vancouver, 31 May – 11 June, 1976 (A/CONF.70/15), chap. II, recommendation B.8, para. C (ii).)

ii-របាយការណ៍របស់គណៈកម្មការទទួលបន្ទុកលំនៅដ្ឋានមនុស្សជាតិ ស្តីពីសម័យប្រជុំលើកទី១១របស់ខ្លួន, ឯកសារបន្ថែម (A/43/8/Add.1), កថាខ័ណ្ឌ១៣ ។ (Report of the Commission on Human Settlements on the work of its eleventh session, Addendum (A/43/8/Add.1), para. 13.)

និងដីធ្លី ដោយអយុត្តិធម៌នោះទេ "iii ។ នៅក្នុង *របៀបវារៈស្តីពីលំនៅដ្ឋាន* រដ្ឋាភិបាលបានប្តេជ្ញាចិត្តដោយខ្លួនឯង " ក្នុងការការពារប្រជាជនទាំងអស់ មិនឱ្យមានការបណ្តេញចេញដោយបំពាន ព្រមទាំងផ្តល់នូវការការពារ និង ដោះស្រាយតាមច្បាប់ ចំពោះរាល់ការបណ្តេញចេញដោយបំពានទាំង ឡាយដែលជាអំពើផ្ទុយនឹងច្បាប់ និងត្រូវយកសិទ្ធិមនុស្សមកពិចារណា [និង] នៅពេលដែលមិនអាចប្រើវិធីផ្សេង ក្រៅពីការបណ្តេញចេញ ដូច្នេះ នៅពេលដែលអាចធ្វើបាន រដ្ឋាភិបាល ត្រូវធានាប្រើវិធីផ្សេងសម្រាប់ ដោះស្រាយឱ្យបានសមស្រប"iv ។ គណៈកម្មការផ្នែកសិទ្ធិមនុស្ស ក៏បាន បញ្ជាក់ដែរថា "ការបណ្តេញចេញដោយបំពាន គឺ រំលោភសិទ្ធិមនុស្សយ៉ាង ធ្ងន់ធ្ងរ "v ។ ប៉ុន្តែថ្មី បើសេចក្តីថ្លែងបញ្ជាក់ទាំងនេះ សំខាន់ដូច្នេះក៏ដោយ ក៏ សេចក្តីថ្លែងការណ៍ នៅទុកបញ្ហាមួយក្នុងបញ្ហាសំខាន់ៗអោយនៅចំហ គឺ

---

iii-របាយការណ៍របស់សន្និសីទអង្គការសហប្រជាជាតិ ស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍ នៅទីក្រុង រីយ៉ូ ឌឺ ចេណេរ៉ូ, ពីថ្ងៃទី៣ ដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩២, ក្បាលទី១ (A/CONF.151/26/Rev.1 (vol.I). ឧបសម្ព័ន្ធ២, របៀបវារៈ២១, ជំពូក៧.៩ ចំណុច ខ ។ (Report of the United Nations Conference on Environment and Development, Rio de Janeiro, 3 – 14 June, 1992, Vol. I (A/CONF.151/26/Rev.1(vol.I), annex II, Agenda 21, chap. 7.9 (b).)

iv-របាយការណ៍របស់សន្និសីទអង្គការសហប្រជាតិ ស្តីពីលំនៅដ្ឋាន (Habitat II) (A/CONF 165/ 14), ឧបសម្ព័ន្ធ២ របៀបវារៈរបស់ Habitat. កថាខ័ណ្ឌ៤០ ចំណុច (n)។ (Report of the United Nations Conferences on Settlements (Habitat II) (A/CONF.165/14, annex II, The Habitat Agenda, para. 40(n).)

v-គណៈកម្មការទទួលបន្ទុកសិទ្ធិមនុស្ស សេចក្តីសម្រេចចិត្តលេខ១៩៩៣/៧៧, កថាខ័ណ្ឌ១ ។ (Commission on Human Rights resolution 1993/77, para.1.)

បញ្ហានៃការកំណត់ថា តើនៅក្នុងស្ថានភាពបែបណា ដែលអាចអនុញ្ញាត្ត អោយមានការបណ្តេញចេញដោយបំពាន ព្រមទាំងបញ្ហានៃការកំណត់នូវប្រភេទនានានៃការការពារ ដែលជាលក្ខខណ្ឌតម្រូវ ក្នុងការធានាបាននូវការគោរពបទបញ្ញត្តិពាក់ព័ន្ធនៅក្នុងកតិកាសញ្ញា។

៣- ការប្រើពាក្យ "**ការបណ្តេញដោយបំពាន**" តាមលក្ខណៈខ្លះ អាចមានបញ្ហា។ កន្សោមពាក្យនេះ ព្យាយាមបង្ហាញន័យនៃ **ការធ្វើតាមទំនើងចិត្ត** និង **ភាពខុសច្បាប់**។ ប៉ុន្តែចំពោះ អ្នកសង្កេតការណ៍ជាច្រើន ការសំអាងលើពាក្យ "**ការបណ្តេញដោយបំពាន**" គឺជាវិធីប្រើពាក្យពីរបញ្ចូលគ្នា (ពាក្យផ្សំ) ដែលមានន័យតែមួយ រីឯអ្នកផ្សេងទៀត បានរិះគន់កន្សោមពាក្យ "**ការបណ្តេញដោយខុសច្បាប់**" ដោយមូលហេតុដែលគេសន្មតថា ច្បាប់ពាក់ព័ន្ធបានថែងពីការការពារយ៉ាងគ្រប់គ្រាន់ ចំពោះសិទ្ធិមានលំនៅដ្ឋាន និងច្បាប់ពាក់ព័ន្ធនានាដែលស្របតាមកតិកាសញ្ញា ដែលមិនមែនជាករណី ដែលចេះតែមានជានិច្ចនោះទេ។ ដូចគ្នានោះដែរ គេបានស្នើឡើងថា ការប្រើពាក្យ "**ការបណ្តេញដោយអយុត្តិធម៌**" មានន័យរឹតតែផ្អែកលើគោលគំនិតបុគ្គលច្រើនជាងថែមទៀត ដោយសារតែពាក្យនេះសំដៅទៅលើការខកខានមិនបានអនុវត្ត ទាល់តែសោះទៅតាមគោលការណ៍ច្បាប់។ សហគមន៍អន្តរជាតិ ជាពិសេសតាមបរិបទនៃគណៈកម្មការផ្នែកសិទ្ធិមនុស្ស បានជ្រើសយកពាក្យ "**ការបណ្តេញចេញដោយបំពាន**" នេះវិញ សំខាន់គឺដោយសារតែ សំណើរផ្សេងៗដែលបានស្នើឡើង ក៏ទទួលរងពី

ភាពខ្វះខាតជាច្រើនដែរ ។ តាមការប្រើនៅក្នុងសេចក្ដីពន្យល់រួម តាំងពីដើមដល់ចប់នោះ បានកំណត់និយមន័យ ពាក្យថា "**ការបណ្ដេញចេញដោយបំពាន**" ថា ការផ្លាស់ចេញជាអចិន្ត្រៃយ៍ ឬជាបណ្ដោះអាសន្ន ដោយផ្ទុយនឹងឆន្ទៈរបស់បុគ្គលម្នាក់ៗរបស់ក្រុមគ្រួសារទាំងឡាយ និង/ឬរបស់សហគមន៍ទាំងមូលពីលំនៅដ្ឋាន ឬដីធ្លី ដែលពួកគាត់កាន់កាប់ដោយគ្មានការការពារតាមច្បាប់សមស្រប ឬគ្មានសិទ្ធិទទួលបាននូវការការពារតាមច្បាប់ ឬតាមមធ្យោបាយផ្សេងៗទៀតឡើយ ។ ប៉ុន្តែការហាមប្រាមលើការបណ្ដេញដោយបំពាន មិនត្រូវអនុវត្តចំពោះការបណ្ដេញចេញដោយប្រើកំលាំងស្របតាមច្បាប់ និងស្របតាមបទបញ្ញត្តិ នៃកតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិមនុស្ស ។

៤- ការអនុវត្តការណ្ដេញចេញដោយបំពាន មានកើតឡើងជាទូទៅ ហើយប៉ះពាល់ដល់ប្រជាជន ទាំងនៅក្នុងប្រទេសអភិវឌ្ឍន៏ និងប្រទេសកំពុងអភិវឌ្ឍន៍។ ដោយសារតែមានចំណងទាក់ទងគ្នា និងភាពពឹងផ្អែកគ្នាទៅវិញទៅមក ដែលមាននៅក្នុងរាល់សិទ្ធិមនុស្ស ដូច្នេះការបណ្ដេញចេញដោយបំពាន តែងតែរំលោភសិទ្ធិផ្សេងៗរបស់មនុស្សជាតិ។ ហេតុដូច្នេះហើយ ទន្ទឹមនឹងការរំលោភយ៉ាងច្បាស់លើសិទ្ធិ ដែលបានចែងនៅក្នុងកតិកាសញ្ញា ការអនុវត្តការបណ្ដេញដោយបំពាន ក៏អាចជាការរំលោភលើសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែរ ដូចជាសិទ្ធិរស់នៅ សិទ្ធិមានសន្តិសុខរបស់មនុស្សគ្រប់រូប សិទ្ធិរួចផុតពីការរំខានលើជីវភាពឯកជន គ្រួសារ និង

លំនៅដ្ឋាន និងសិទ្ធិទទួលបានភោគៈប្រកបដោយសន្តិវិធី ។

៥- ថ្វីបើការអនុវត្តការបណ្តេញចេញដោយបំពាន អាចកើតមានជាពិសេសនៅតាមតំបន់ក្រីក្រក្នុងទីប្រជុំជនក៏ដោយ ក៏វាអាចកើតឡើងដោយទាក់ទងទៅនឹងការផ្ទេរប្រជាជនដោយបង្ខំ ការអោយចាកចេញដោយបង្ខំចិត្តពីកន្លែងរស់នៅក្នុងផ្ទៃប្រទេស ការបង្ខំតាំងទីលំនៅថ្មីដោយសារ ស្ថានភាពសង្គ្រាម ការចាកចេញពីកន្លែង រស់នៅក្នុងទ្រង់ទ្រាយធំ ឬចលនាជនភៀសខ្លួនដែរ ។ នៅក្នុងស្ថានភាពទាំងអស់នេះ សិទ្ធិមានលំនៅដ្ឋានសមរម្យ និងសិទ្ធិមិនទទួលរងនូវការបណ្តេញដោយបំពាន អាចនឹងត្រូវរំលោភបំពានតាមរយៈអំពើ ឬការបំភ្លេចចោលមួយចំនួនធំ ដែលជាអំពើ ឬការបំភ្លេចរបស់រដ្ឋភាគីនានា ។ សូម្បីតែនៅក្នុងស្ថានភាពដែលចាំបាច់ត្រូវប្រឈមនឹងការកំហិតសិទ្ធិបែបណាក៏ដោយ ក៏តម្រូវឱ្យគោរពតាមមាត្រា ៤ នៃកតិកាសញ្ញានេះទាំងស្រុង ដើម្បីឱ្យការរឹតបន្តឹងដាច់ខាតត្រូវបាន "សម្រេចដោយច្បាប់ រហូតដល់កម្រិតមួយដែលអាចស៊ីចង្វាក់ នឹងសិទ្ធិទាំងនេះ [ដូចជាសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌] និងសំរាប់តែ ដើម្បីលើកកំពស់ សុខមាលភាពទូទៅ ក្នុងសង្គមប្រជាធិបតេយ្យតែប៉ុណ្ណោះ" ។

៦- ស្ថានភាពនៃការបណ្តេញចេញដោយបំពានជាច្រើន មានពាក់ព័ន្ធនឹងការប្រើអំពើហិង្សា ដូចជាការបណ្តេញ ដែលបណ្តាលមកពីសង្គ្រាមអន្តរ-ជាតិ ការជំលោះផ្ទៃក្នុង និងអំពើហិង្សានៅក្នុងសហគមន៍ ឬអំពើហិង្សា

របស់ជនជាតិភាគតិច។

៧- ស្ថានភាពនៃការបណ្តេញចេញដោយបំពានផ្សេងៗទៀត កើតឡើង *ក្រោមផ្លាក* **អភិវឌ្ឍន៍**។ ការបណ្តេញចេញបែបនេះ អាចនឹងត្រូវអនុវត្ត ដោយសារវិវាទលើសិទ្ធិដីធ្លីលើគម្រោងអភិវឌ្ឍន៍ និងហេដ្ឋារចនាសម្ព័ន្ធ ដូចជា ការសង់ទំនប់វារីអគ្គីសនី ឬគម្រោងថាមពលខ្នាតធំផ្សេងៗ ដោយសារវិធានការលទ្ធកម្មដីធ្លី ដែលពាក់ព័ន្ធនឹងកម្មវិធីរៀបចំតំបន់ទីប្រជុំជនក្នុងក្រុងជាថ្មី ការជួសជុលកែលំអលំនៅដ្ឋាន និងការកែលំអសោភ័ណភាពក្រុង ការឈូសឆាយដីសម្រាប់ធ្វើកសិកម្ម ការចាប់ដីទុកទិញលក់បែបអនាធិបតេយ្យ ឬការរៀបចំព្រឹត្តិការណ៍កីឡាធំៗ ដូចជាកីឡាអូឡាំពិក ជាដើម។

៨- សំខាន់បំផុតកាតព្វកិច្ចទាំងឡាយរបស់រដ្ឋភាគី ដែលត្រូវគោរពតាមកតិកាសញ្ញា ទាក់ទងនឹងការបណ្តេញចេញដោយបំពាន គឺផ្អែកលើមាត្រា ១១.១ ដោយបកស្រាយឱ្យស្របទៅនឹងបទបញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀត។ ជាពិសេស មាត្រា ២.១ ដាក់កាតព្វកិច្ចឱ្យរដ្ឋភាគីទាំងឡាយ ប្រើ "គ្រប់មធ្យោបាយសមស្រប" ដើម្បីលើកកំពស់សិទ្ធិមានលំនៅដ្ឋានសមរម្យ។ ប៉ុន្តែ តាមទស្សនៈនៃលក្ខណៈវិធីអនុវត្តន៍ការបណ្តេញចេញដោយបំពាន ការសំអាងមាត្រា ២.១ ដើម្បីទទួលបានសមិទ្ធិផលជឿនលឿន ដោយផ្អែកលើធនធានដែលមាន គឺមិនងាយនឹងសមស្របឡើយ។ រដ្ឋនេះឯង ត្រូវតែចៀសឱ្យផុតពីការបណ្តេញចេញដោយបំពាន ត្រូវធានាថា ច្បាប់ត្រូវបាន

អនុវត្ត ដើម្បីប្រឆាំងនឹងភ្នាក់ងារ ឬភាគីទីបីដែលជាអ្នកអនុវត្តការបណ្តេញចេញដោយបំពាន (ដូចមានចែងនៅក្នុងចំណុច ៣ ខាងលើ)។ លើសពីនេះទៅទៀត វិធីដោះស្រាយនេះត្រូវបានលើកឡើងនៅក្នុង មាត្រា ១៧.១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយបំពេញបន្ថែមលើសិទ្ធិមិនទទួលរងការបណ្តេញដោយបំពាន ឱ្យចេញដោយគ្មានការការពារសមរម្យ។ ក្នុងចំណោមបទបញ្ញត្តិទាំងនោះ ទទួលស្គាល់នូវសិទ្ធិការពារទល់នឹង "ការជ្រៀតជ្រែក តាមទំនើងចិត្ត ឬការជ្រៀតជ្រែកដោយខុសច្បាប់" នៅក្នុងលំនៅដ្ឋានរបស់នរណាម្នាក់ឡើយ។ ត្រង់នេះ ត្រូវកត់សម្គាល់ថា កាតព្វកិច្ចរបស់រដ្ឋភាគី ក្នុងការធានាឱ្យមានការគោរពសិទ្ធិនោះមិនមែនដោយសារ ការពិចារណាលើធនធានដែលរដ្ឋនោះមាននោះទេ។

៩- មាត្រា២.១ នៃកតិកាសញ្ញានេះ តម្រូវឱ្យរដ្ឋភាគីប្រើ "រាល់មធ្យោបាយសមស្រប" រួមទាំងការអនុម័តវិធានការនៃនីតិបញ្ញត្តិ ដើម្បីលើកកំពស់សិទ្ធិគប់បែបយ៉ាងដែលកតិកាសញ្ញានេះបានការពារ។ ទោះបីជា គណៈកម្មាធិការ បានគូសបញ្ជាក់នៅក្នុងសេចក្តីពន្យល់រួម លេខ ៣ របស់ខ្លួន (នៅឆ្នាំ១៩៩០) ថាវិធានការបែបនោះ មិនចាំបាច់ត្រូវតែទាក់ទងនឹងសិទ្ធិទាំងអស់ក៏ដោយ ក៏វាបានបង្ហាញយ៉ាងច្បាស់ថា ការអនុមត័ច្បាបប្រឆាំងនឹងការបណ្តេញចេញដោយបំពានជ ាមូលដ្ឋានយ៉ាងសំខាន់ ដែលជាការបង្កើតបព័ន្ធការពារមួយប្រកបដោយប្រសិទ្ធភាព។ ការអនុម័តច្បាប់បែបនោះ គប្បីត្រូវបញ្ចូលនូវវិធានការដែល (១) ផ្តល់នូវការការពារសុវត្ថិភាព

ក្នុងការកាន់កាប់ឱ្យបានខ្លាំងបំផុតដែលអាចធ្វើទៅបានជូនអ្នកកាន់កាប់លំនៅដ្ឋាន និងដីធ្លី (២) ស្របគ្នានឹងកតិកាសញ្ញា និង (៣) ត្រូវរៀបចំឡើងឱ្យបានតឹងរឹងបំផុត ដើម្បីគ្រប់គ្រងស្ថានភាពដែលអាចអនុវត្តការបណ្តេញចេញ។ ច្បាប់នោះ ត្រូវតែអនុវត្តចំពោះភ្នាក់ងារទាំងអស់ដែលអនុវត្តទៅតាមអំណាចរបស់រដ្ឋ ឬចំពោះអ្នកដែលទទួលខុសត្រូវចំពោះការបណ្តេញចេញ។ ម្យ៉ាងទៀត ទាក់ទងនឹង និន្នាការរីកចម្រើន នៅតាមរដ្ឋខ្លះដែលរដ្ឋាភិបាលឈានទៅរកការកាត់បន្ថយការទទួលខុសត្រូវរបស់ខ្លួនយ៉ាងខ្លាំងក្នុងផ្នែកលំនៅដ្ឋាន រដ្ឋភាគីត្រូវធានាថា វិធានការនីតិបញ្ញត្តិ និងវិធានការផ្សេងៗទៀត មានលក្ខណៈគ្រប់គ្រាន់ ដើម្បីទប់ស្កាត់ និងបើសិនជាចាំបាច់ធ្វើការដាក់ទណ្ឌកម្មលើការបណ្តេញចេញដោយបំពានដែលអនុវត្តដោយគ្មានវិធានការសុវត្ថិភាពសមស្រប ធ្វើដោយមនុស្សមួយចំនួន ឬដោយអង្គភាពនានា។ ហេតុដូច្នេះ រដ្ឋជាភាគី គប្បីពិនិត្យលើច្បាប់ និងគោលនយោបាយពាក់ព័ន្ធឡើងវិញ ដើម្បីធានាថាច្បាប់ និងគោលនយោបាយទាំងនោះ ស្របទៅតាមកាតព្វកិច្ចដែលកើតចេញពីសិទ្ធិមានលំនៅដ្ឋានសមរម្យ និងលុបចោល ឬធ្វើវិសោធនកម្មលើច្បាប់ ឬគោលនយោបាយទាំងឡាយណាដែលមិនស្របទៅតាមលក្ខខណ្ឌរបស់កតិកាសញ្ញា។

១០- ស្ត្រី កុមារ យុវជន មនុស្សចាស់ ជនជាតិដើមភាគតិច ជាតិពន្ធុ និងជនជាតិផ្សេងៗទៀត ព្រមទាំងបុគ្គល និងក្រុមដែលងាយរងគ្រោះទាំង

អស់នេះ សុទ្ធតែទទួលរងមិនសមាមាត្រនៃការបណ្តេញដោយបំពាន។ ស្ត្រី ស្ថិត នៅក្នុងក្រុមទាំងអស់ដែលងាយរងគ្រោះ តែងតែទទួលបាននូវទំហំនៃ ស្ថានភាព ឬទម្រង់នៃការរើសអើង ដែលតែងតែកើតមានឡើងនៅក្នុង រឿងដែលទាក់ទងនឹងសិទ្ធិកម្មសិទ្ធិ (រួមទាំងកម្មសិទ្ធិ លំនៅដ្ឋានផង) ឬសិទ្ធិ ប្រើប្រាស់អចលវត្ថុ ឬការអាស្រ័យនៅ ព្រមទាំងភាពងាយប្រឈមរបស់ ស្ត្រី ជាពិសេសផ្សេងទៀត ចំពោះអំពើហិង្សា និងការរំលោភសេពសន្ថវៈ នៅពេលដែលគេគ្មានលំនៅដ្ឋានរស់នៅ។ បទប្បញ្ញត្តិនៃភាពមិនរើសអើង នៅក្នុងមាត្រា ២.២ និងមាត្រា ៣ នៃកតិកាសញ្ញាបានដាក់កាតព្វកិច្ចបន្ថែម ទៅរដ្ឋាភិបាល ដើម្បីធានាអោយបានថា នៅពេលមានការបណ្តេញចេញ រដ្ឋ ត្រូវចាត់វិធានការអនុវត្តសមស្រប ដើម្បីធានាមិនអោយការរើសអើង នៅ ទីណាដែលមានការបណ្តេញចេញ។

១១- ដោយការបណ្តេញចេញខ្លះ អាចជាការបណ្តេញត្រឹមត្រូវតាមច្បាប់ ដូចជាក្នុងករណីខកខានមិនបានបង់ថ្លៃឈ្នួលជាបន្តបន្ទាប់ ឬ ក្នុងករណីធ្វើ ឱ្យខូចខាតទ្រព្យសម្បត្តិដែលជួលដោយគ្មានមូលហេតុសមរម្យ ដូច្នេះ នេះក៏ ជាការទទួលខុសត្រូវរបស់អាជ្ញាធរពាក់ព័ន្ធដែលត្រូវធានាថា ការបណ្តេញ ចេញបែបនោះ ត្រូវបានអនុវត្តទៅតាមលក្ខណៈដែលមានការធានាដោយ ច្បាប់ ដែលច្បាប់នេះស្របនឹងកតិកាសញ្ញាផង និងរាល់វិធានទាំងនោះត្រូវ បើកផ្លូវដោះស្រាយខាងច្បាប់ និងការជួសជុលគ្រប់បែបយ៉ាងសម្រាប់ អនុវត្តចំពោះប្រជាជនដែលទទួលរងការបណ្តេញចេញនោះ។

១២- ការបណ្តេញដោយបំពាន និងការវាយកំទេចផ្ទះ ដែលគេប្រើជាវិធានដាក់ពិន័យ ក៏មិនស្រេបនឹងបទដ្ឋាននៃកតិកាសញ្ញាដែរ។ ដូចគ្នានោះដែរ គណៈកម្មាធិការ បានកត់សម្គាល់អំពីកាតព្វកិច្ចនានា ដែលបានចែងនៅក្នុង *អនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងពិធីសារចាប់ពីឆ្នាំ១៩៧៧* ដែលទាក់ទងនឹងការហាមប្រាមលើការចាកចេញដោយបង្ខំចិត្ត ពីលំនៅដ្ឋានរបស់ជនស៊ីវិល និងការបំផ្លាញកម្មសិទ្ធិឯកជន ព្រោះថាការធ្វើបែបនេះ ជាការអនុវត្តការបណ្តេញចេញដោយបំពាន។

១៣- មុនពេលអនុវត្តការបណ្តេញចេញណាមួយ និងជាពិសេសទាក់ទងនឹងការបណ្តេញក្រុមមនុស្សច្រើន រដ្ឋភាគី ត្រូវធានាថា មានការស្វែងរកជម្រើសសមស្របជាច្រើនឱ្យអស់លទ្ធភាព ដោយពិគ្រោះយោបល់ជាមួយប្រជាជនដែលជាអ្នកទទួលរងផលប៉ះពាល់ពីការបណ្តេញចេញ ក្នុងទស្សនៈមួយ ដើម្បីបញ្ចៀសការប្រើកម្លាំង ឬ យ៉ាងហោចណាស់ត្រូវកាត់បន្ថយការប្រើកម្លាំងនោះឱ្យនៅកម្រិតតិចបំផុត។ គប្បីត្រូវផ្តល់ជូនទៅប្រជាជនដែលជាអ្នកទទួលរងនូវការបណ្តេញចេញ នូវវិធីដោះស្រាយ ឬនីតិវិធីតាមច្បាប់តាមរយៈលិខិតបញ្ជាពីការបណ្តេញចេញ។ រដ្ឋភាគី ក៏គប្បីត្រូវយល់អោយឃើញថា បុគ្គលទាំងអស់ដែលពាក់ព័ន្ធ មានសិទ្ធិទទួលបាននូវសំណងសមរម្យសម្រាប់ទ្រព្យសម្បត្តិទាំងចលនទ្រព្យ និងអចលទ្រព្យ ដែលត្រូវទទួលរងការខូចខាតដោយសារការបណ្តេញចេញនោះ។ តាមន័យនេះ យើងត្រូវយោងទៅមាត្រា ២.៣ នៃ*កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង*

*នយោបាយ* ដែលតម្រូវឱ្យរដ្ឋភាគី ធានានូវ "វិធីដោះស្រាយមានប្រសិទ្ធភាព" ជូនប្រជាជនទាំងឡាយដែលសិទ្ធិរបស់គាត់ត្រូវគេរំលោភសិទ្ធិ និងធានាកាតព្វកិច្ចរបស់"អាជ្ញាធរមានសមត្ថកិច្ច(ក្នុងការ) អនុវត្តដោះស្រាយទាំងនោះអោយបាន នៅពេលដែលអាជ្ញាធរមានភារកិច្ចដោះស្រាយ"។

១៤- ក្នុងករណីដែលការបណ្តេញចេញ ត្រូវបានចាត់ទុកថាត្រឹមត្រូវតាមផ្លូវច្បាប់ ការបណ្តេញចេញនោះ ត្រូវអនុវត្តឱ្យបានម៉ឹងម៉ាត់ទៅតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងស្របតាមគោលការណ៍ទូទៅ ស្តីពីភាពសមហេតុផល និងភាពសមាមាត្រ។ ត្រង់ចំណុចនេះ វាជាការសមហេតុផល ជាពិសេសក្នុងការរំលឹកដល់ *សេចក្តីពន្យល់រួម លេខ១៦* របស់គណៈកម្មាធិការសិទ្ធិមនុស្ស ដែលទាក់ទងនឹងមាត្រា ១៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលចែងថា ការជ្រៀតជ្រែកលំនៅដ្ឋានរបស់ជនណាម្នាក់ អាចប្រព្រឹត្តទៅបានតែក្នុង "ករណីដែលច្បាប់បានកំណត់"។ គណៈកម្មាធិការ បានសង្កេតឃើញថា ច្បាប់ "គប្បីត្រូវស្របតាមបទប្បញ្ញត្តិ ទិសដៅ និងគោលបំណងនៃកតិកាសញ្ញានេះ ហើយទោះជាយ៉ាងណាក៏ដោយ គប្បីត្រូវមានហេតុផលស្របតាមកាលៈទេសៈពិសេសនោះ"។ គណៈកម្មាធិការ ក៏បានបញ្ជាក់ដែរថា "ច្បាប់ពាក់ព័ន្ធ ត្រូវចែងលំអិតអំពីករណីជាក់លាក់ ដែលអាចអនុញ្ញាតឱ្យមានការជ្រៀតជ្រែកទាំងនេះបាន "។

១៥- ការការពារនីតិវិធីសមស្រប និងនីតិវិធីត្រឹមត្រូវ គឺជាចំណុចសំខាន់នៃសិទ្ធិមនុស្សទាំងអស់ ប៉ុន្តែជាពិសេស វាសមស្របទៅនឹងបញ្ហា ដូចជាការបណ្តេញចេញដោយបំពាន ដែលប៉ះពាល់ដោយផ្ទាល់ដល់សិទ្ធិច្រើនទៀត ដែលបានទទួលស្គាល់ក្នុងកតិកាសញ្ញាអន្តរជាតិទាំងពីរ ស្តីពីសិទ្ធិមនុស្ស ។ គណៈកម្មាធិការ ចាត់ទុកថា ការការពារនីតិវិធី ដែលគប្បីត្រូវអនុវត្តចំពោះការបណ្តេញចេញដោយបំពាន ដូចជា៖ (ក) ឱកាសសំរាប់ការពិគ្រោះយោបល់ពិតប្រាកដជាមួយបុគ្គលដែលរងផលប៉ះពាល់ (ខ) ការជូនដំណឹងជាមុន ត្រូវទុកពេលវេលាគ្រប់គ្រាន់ និងសមហេតុផលដល់បុគ្គលដែលរងផលប៉ះពាល់ នៅមុនកាលបរិច្ឆេទនៃបណ្តេញចេញ (គ) ការផ្តល់ព័ត៌មានអំពីការបណ្តេញចេញដែលបំរុងធ្វើ ហើយត្រូវប្រាប់ឱ្យពួកគាត់ដឹងផងដែរ ប្រសិនជាមានជំរើសអ្វីផ្សេងពីនេះសំរាប់ការប្រើប្រាស់ដីធ្លី ឬលំនៅដ្ឋាននោះ និងទុកពេលវេលាគ្រប់គ្រាន់ឱ្យអ្នករងផលប៉ះពាល់ (ឃ) ជាពិសេសនៅពេលដែលពាក់ព័ន្ធនឹងមនុស្សច្រើនក្រុម នៅក្នុងអំឡុងពេលនៃការបណ្តេញចេញនោះ ត្រូវតែមានវត្តមានមន្ត្រីរដ្ឋាភិបាល ឬតំណាងរបស់ពួកគាត់ (ង) បុគ្គលគ្រប់រូប ដែលអនុវត្តការបណ្តេញចេញ ត្រូវមានអត្តសញ្ញាណត្រឹមត្រូវ (ច) ការបណ្តេញចេញ មិនត្រូវធ្វើ ជាពិសេសនៅពេលមានអាកាសធាតុអាប់អួរ ឬនៅពេលយប់ឡើយ លើកលែងតែមានការយល់ព្រមពីអ្នករងផលប៉ះពាល់ (ឆ) ការផ្តល់ការដោះស្រាយតាមផ្លូវច្បាប់ ហើយ (ជ) ប្រសិនជាអាចធ្វើបាន ត្រូវផ្តល់ជំនួយផ្នែកច្បាប់ដល់អ្នក

ដែលត្រូវការជំនួយនេះ ដើម្បីស្វែងរកដោះស្រាយពីតុលាការ ។

១៦- ការបណ្តេញចេញនោះ មិនត្រូវបណ្តាលឱ្យបុគ្គលទាំងឡាយ គ្មានលំនៅដ្ឋានរស់នៅ ឬបណ្តាលឱ្យងាយនឹងទទួលរងការរំលោភសិទ្ធិមនុស្សផ្សេងៗទៀតឡើយ ។ ប្រសិនជាអ្នករងផលប៉ះពាល់ទាំងនោះ មិនអាចផ្គត់ផ្គង់ខ្លួនឯងបានទេ រដ្ឋភាគីត្រូវចាត់គ្រប់វិធានការសមស្រប ដោយប្រើប្រាស់ជាអតិបរមានូវធនធានខ្លួនមាន ដើម្បីថានាថា ផ្ទះសម្បែង ការតាំងទីលំនៅថ្មីមានលក្ខណៈសមរម្យ ឬមានសិទ្ធិអាចប្រើប្រាស់ដីធ្លី ដែលឱ្យផលច្រើនដែលមានតាមករណីជាក់ស្តែង ។

១៧-គណៈកម្មាធិការ ដឹងថា គំរោងអភិវឌ្ឍន៍ជាច្រើន ដែលទទួលមូលនិធិពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ដែលមានទីតាំងក្នុងដែនដីរបស់រដ្ឋភាគី បាននាំឱ្យមានការបណ្តេញចេញដោយបំពានជាច្រើន ។ ក្នុងបញ្ហានេះ គណៈកម្មាធិការ សូមរំលឹកដល់សេចក្តីពន្យល់រួមលេខ ២ របស់ខ្លួន (១៩៩០) ដែលបញ្ជាក់ថា "ភ្នាក់ងារអន្តរជាតិ គប្បីត្រូវចៀសវាងជាដាច់ខាត មិនត្រូវចូលពាក់ព័ន្ធ ក្នុងគំរោងទាំងឡាយណាដែល ដូចជា ... ជំរុញឱ្យមាន ឬអនុវត្តភាពរើសអើងចំពោះបុគ្គលទាំងឡាយ ឬក្រុមមនុស្សផ្ទុយនឹងបទប្បញ្ញត្តិ នៃកតិកាសញ្ញានេះ ឬពាក់ព័ន្ធនឹងការបណ្តេញចេញក្នុងទ្រង់ទ្រាយធំ ឬការឱ្យមនុស្សចាកចេញពីដីធ្លី ឬលំនៅដ្ឋានរបស់ខ្លួន ដោយមិនផ្តល់ការការពារ និងសំណងសមរម្យនោះឡើយ ។ ក្នុងដំណាក់កាល

នីមួយៗនៃគំរោងអភិវឌ្ឍន៍មួយ ត្រូវខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង ដើម្បីធានាថា សិទ្ធិទាំងឡាយដែលមានចែងក្នុងកតិកាសញ្ញានេះ ត្រូវបានយកមកពិចារណាឱ្យបានល្អិតល្អន់ "vi ។

១៨- ស្ថាប័នមួយចំនួនដូចជាធនាគារពិភពលោក អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ **(OECD)** បានអនុម័តគោលការណ៍ណែនាំ ស្តីពីការតាំងទីលំនៅថ្មី ក្នុងគោលដៅកាត់បន្ថយកំរិតនៃការឈឺចាប់របស់មនុស្សទាក់ទងនឹងការបណ្តេញចេញដោយបំពាន។ ការអនុវត្តន៍បែបនេះ ជារឿយតែងតែកើតមានទន្ទឹមគ្នានឹងគំរោងអភិវឌ្ឍន៍ទ្រង់ទ្រាយធំៗ ដូចជា ការសាងសង់ទំនប់ទឹក និងគំរោងផលិតថាមពលធំៗផ្សេងទៀត។ ដើម្បីឆ្លើយតបនឹងកាតព្វកិច្ចដែលមានចែងនៅក្នុងកតិកាសញ្ញា ការគោរពទាំងស្រុងនូវគោលការណ៍ណែនាំនេះ គឺជាការសំខាន់ណាស់ សំរាប់ទីភ្នាក់ងារផ្ទាល់ និងសំរាប់រដ្ឋភាគីនៃកតិកាសញ្ញា។ ក្នុងបញ្ហានេះ គណៈកម្មាធិការ សូមរំលឹកដល់ សេចក្តីថ្លែងការណ៍នៅក្នុង *សេចក្តីប្រកាស និងកម្មវិធីសកម្មភាពទីក្រុងវីយ៉ែន* ដែលចែងថា "ទន្ទឹមនឹងការអភិវឌ្ឍន៍ជួយសម្រួលដល់ការទទួលបានសិទ្ធិមនុស្សទាំងអស់ក្តី ក៏ការខ្វះការអភិវឌ្ឍន៍ មិនអាចត្រូវបានគេលើកសំអាងថាជាការកាត់បន្ថយសិទ្ធិមនុស្ស ដែលទទួលស្គាល់ជាអន្តរជាតិ នោះឡើយ "។ (ផ្នែក១ កថាខ័ណ្ឌ១០)

---

vi- E/1990/23, ឧបសម្ព័ន្ធ៣, កថាខ័ណ្ឌ ៦ និង៨ ចំណុច d ។ (E/1990/23, annex II, para. 6 and 8(d).)

១៩- តាមគោលការណ៍ណែនាំស្ដីពីការធ្វើរបាយការណ៍ ដែលអនុម័តដោយគណៈកម្មាធិការ បានស្នើឱ្យរដ្ឋភាគី ផ្ដល់នូវព័ត៌មានផ្សេងៗទៀត ដែលទាក់ទងដោយផ្ទាល់ទៅនឹងវិធីអនុវត្តការបណ្ដេញចេញដោយបំពាន។ ព័ត៌មានទាំងនេះរាប់ទាំង (ក) "ចំនួនប្រជាជនដែលត្រូវបានបណ្ដេញចេញ នៅក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ និងចំនួនប្រជាជន ដែលបច្ចុប្បន្ន មិនបានទទួលការការពារតាមផ្លូវច្បាប់ប្រឆាំងនឹងការបណ្ដេញចេញដោយបំពាន ឬ ការបណ្ដេញចេញតាមរូបភាពផ្សេងៗទៀត", (ខ) "ច្បាប់ទាក់ទងនឹងសិទ្ធិអ្នកជួល មានសុវត្ថិភាពក្នុងការកាន់កាប់អចលនទ្រព្យ ដើម្បីការពារមិនឱ្យមានការបណ្ដេញចេញ" និង (គ) "ច្បាប់ហាមប្រាមការបណ្ដេញចេញតាមរូបភាពណាមួយ"vii ។

២០- ត្រូវផ្ដល់ផងដែរនូវព័ត៌មានទាក់ទងនឹង "វិធានការដែលបានចាត់នៅក្នុងអំឡុងពេលអនុវត្ត ដូចជាកម្មវិធី រៀបចំកែលំអទីក្រុង គំរោងអភិវឌ្ឍន៍ឡើងវិញ ការអភិវឌ្ឍន៍នៅនឹងកន្លែង ការរៀបចំព្រឹត្តិការណ៍អន្តរជាតិ (ដូចជា ការប្រកួតកីឡាអូឡាំពិក និងកីឡាផ្សេងៗទៀត ការតាំងពិព័រណ៍ សន្និសីទជាដើម), និងយុទ្ធនាការ "សោភ័ណភាពទីក្រុង" ជាដើម ដែលធានាបាននូវការការពារមិនឱ្យមានការបណ្ដេញចេញ ឬដែលធានាបាននូវការផ្ដល់លំនៅដ្ឋានវិញ ដោយផ្អែកលើការយល់ព្រមទាំងសងខាង ដោយ

vii-E/C.12/1999/8, ឧបសម្ព័ន្ធ៤។ (E/C.12/1999/8, annex IV.)

អ្នកទាំងឡាយដែលកំពុងរស់នៅលើ ឬក្បែរការដ្ឋានដែលរងការបណ្តេញនោះ"viii ។ ក៏ប៉ុន្តែមានរដ្ឋភាគីតែពីរ-បី ប៉ុណ្ណោះ ដែលបានបញ្ចូលផ្តល់ព័ត៌មានដែលចង់បាននោះទៅក្នុងរបាយការណ៍របស់ខ្លួន ដែលបានដាក់ជូនគណៈកម្មាធិការ ។ ហេតុដូច្នេះហើយ គណៈកម្មាធិការ សូមបញ្ជាក់ច្បាស់អំពីសារៈសំខាន់នៃគុណភាព ព័ត៌មានដែលខ្លួនបានទទួល ។

២១- រដ្ឋភាគីខ្លះបានបញ្ជាក់ថា គ្មានព័ត៌មានបែបនេះទេ ។ គណៈកម្មាធិការសូមរំលឹកថា ការពិនិត្យតាមដានប្រកបដោយប្រសិទ្ធភាព លើសិទ្ធិមានលំនៅដ្ឋានសមរម្យ ទាំងដោយរដ្ឋាភិបាលពាក់ព័ន្ធ ឬដោយគណៈកម្មាធិការមិនអាចប្រព្រឹត្តទៅបានទេ បើអវត្តមានការប្រមូលព័ត៌មានសមស្របបែបនេះ ហើយសូមសំណូមពររដ្ឋភាគីទាំងអស់ឱ្យធានាថា ព័ត៌មានចាំបាច់ៗត្រូវបានប្រមូល និងត្រូវឆ្លុះបញ្ចាំងលើរបាយការណ៍ ដែលខ្លួនបានដាក់ជូនតាមកតិកាសញ្ញានេះ ។

viii-ដូចខាងលើ ។

# គោលការណ៍ជាមូលដ្ឋាន និង គោលការណ៍ណែនាំ

# ស្ដីពី

# ការបណ្ដេញចេញ និងការចាកចេញដោយបង្ខំចិត្ត ផ្អែកលើការអភិវឌ្ឍន៍ *

## I. វិសាលភាព និង ចរិតលក្ខណៈ

១. រដ្ឋមានកាតព្វកិច្ចទប់ស្កាត់ និងរារាំងការបណ្ដេញចេញដោយបំពានពីលំនៅដ្ឋាន និងដីធ្លី ដែលកាតព្វកិច្ច ទាំងនេះកើតចេញពីលិខិតុបករណ៍គតិយុត្តិអន្តរជាតិមួយចំនួន ដែលការពារសិទ្ធិមានលំនៅដ្ឋានសមរម្យ និងសិទ្ធិមនុស្សពាក់ព័ន្ធឯទៀត ។ លិខិតុបករណ៍ទាំងនេះ រួមមាន សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (មាត្រា១១ កថាខ័ណ្ឌទី១) អនុសញ្ញាស្ដីពី សិទ្ធិកុមារ (មាត្រា២៧ កថាខ័ណ្ឌទី៣) បញ្ញត្តិស្ដីពីការមិនរើសអើង មានចែងក្នុងមាត្រា១៤ កថាខ័ណ្ឌទី២ (ជ) នៃអនុសញ្ញាស្ដីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងមាត្រា ៥ (ង) នៃអនុសញ្ញាស្ដីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ។

២. លើសពីនេះ និងស្របតាមគោលការណ៍អវិភាគភាពនៃសិទ្ធិមនុស្ស មាត្រា១៧ នៃកតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និង

---

* ឧបសម្ព័ន្ធ ១ នៃរបាយការណ៍របស់អ្នករាយការណ៍ពិសេស ស្ដីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ ជាផ្នែកមួយនៃសិទ្ធិមានកំរិតជីវភាពសមរម្យ A/HRC/4/18

សិទ្ធិនយោបាយ ចែងថា " គ្មានជនណាម្នាក់ ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន សំបុត្រឆ្លើយឆ្លងរបស់ខ្លួន " មាត្រានេះចែងទៀតថា "ជនគ្រប់រូបមានសិទ្ធិឲ្យច្បាប់ការពារប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់បែបនេះ" ។ មាត្រា ១៦ កថាខ័ណ្ឌទី១ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារមានបញ្ញត្តិស្រដៀងគ្នានេះផងដែរ ។ ការយោងដល់បញ្ញត្តិឯទៀតក្នុងច្បាប់អន្តរជាតិ រួមមាន មាត្រា២១ នៃអនុសញ្ញាឆ្នាំ១៩៥១ ពាក់ព័ន្ធនឹងឋានៈជនភៀសខ្លួន មាត្រា១៦ នៃអនុសញ្ញាលេខ១៦៩ របស់អង្គការពលកម្មអន្តរជាតិ ស្ដីពី ជនជាតិដើមភាគតិច និងក្រុមកុលសម្ព័ន្ធ នៅបណ្ដាប្រទេសឯករាជ្យ(១៩៨៩) និងមាត្រា៤៩ នៃអនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងនឹងការការពារជនស៊ីវិលក្នុងពេលមានសង្គ្រាម ចុះថ្ងៃ១២ ខែសីហា ឆ្នាំ១៩៤៩ (អនុសញ្ញាទីក្រុងហ្សឺណែវទីបួន) ។

៣. គោលការណ៍ណែនាំនេះ និយាយអំពីភាពជាប់ជំពាក់នៃសិទ្ធិមនុស្សទៅនឹងការបណ្ដេញចេញ និងការចាកចេញដោយបង្ខំចិត្តផ្អែកលើការអភិវឌ្ឍន៍ទីក្រុង និង ឬ តំបន់ជនបទ ។ គោលការណ៍ណែនាំទាំងនេះ តំណាងឲ្យការបង្កើតគោលការណ៍សិទ្ធិមនុស្សមួយដែលមានលក្ខណៈទូលំទូលាយថែមទៀត ស្ដីពីការចាកចេញដោយបង្ខំចិត្ត ផ្អែកលើការអភិវឌ្ឍន៍(E/CN.4/Sub.2/1997/7, annex)។ គោលការណ៍ទាំងនេះ ផ្អែកលើច្បាប់សិទ្ធិមនុស្ស អន្តរជាតិ និងស្របតាមសេចក្ដីពន្យល់រួមលេខ ៤ (១៩៩១) និងសេចក្ដីពន្យល់រួម លេខ ៧ (១៩៩៧) របស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្ប

ធម៌ គោលការណ៍ណែនាំស្តីពីការភៀសសឹក (E/CN. 4/1998/53/ Add.2) គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបានការដោះស្រាយ និងការជួសជុលសំណងការខូចខាតដល់ជនរងគ្រោះដោយការរំលោភលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ឬការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានអនុម័ត ដោយមហាសន្និបាត ក្នុងសេចក្តីសំរេចចិត្តរបស់ខ្លួនលេខ៦០/១៤៧ និងគោលការណ៍ស្តីពីការដោះស្រាយដ៏មានប្រសិទ្ធភាព ចំពោះលំនៅដ្ឋាន និងទ្រព្យសម្បត្តិសំរាប់ជនភៀសខ្លួន និងជនភៀសសឹក (សូមមើល E/CN.4/Sub.2/ 2005 /17 and Add.1).

៤. ដោយគិតគូរត្រឹមត្រូវអំពីនិយមន័យទាំងអស់ពាក់ព័ន្ធនឹងការ "ការបណ្តេញចេញដោយបំពាន" ក្នុងបរិបទនៃបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ គោលការណ៍ណែនាំនេះ អនុវត្តចំពោះអំពើ និងឬការខកខានទាំងឡាយ ដែលទាក់ទងនឹងការចាកចេញដោយបង្ខំចិត្ត ឬដោយមិនស្ម័គ្រចិត្តនៃបុគ្គល ក្រុម និងសហាគមន៍នានាពីលំនៅដ្ឋាន និងឬដីធ្លី និង ធនធានដីរួម ដែលបានកាន់កាប់ ឬ បានអាស្រ័យផលជាហេតុនាំឲ្យបាត់បង់ ឬកំរិត ដល់លទ្ធភាពរបស់បុគ្គល ក្រុម ឬសហាគមន៍មួយ ក្នុងការរស់នៅ ឬធ្វើការក្នុងលំនៅដ្ឋាន និវេសនដ្ឋាន ឬទីតាំងដោយមិនផ្តល់និងទទួលបានការការពារត្រឹមត្រូវតាមផ្លូវច្បាប់ ឬការការពារផ្សេងទៀត។[i]

[i]-ការហាមប្រាមការបណ្តេញចេញដោយបំពាននេះ មិនអនុវត្តចំពោះការបណ្តេញចេញទាំងឡាយណាដែលធ្វើឡើងតាមផ្លូវច្បាប់ និងស្របតាមបញ្ញត្តិនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានានោះទេ ។

៥. ការបណ្តេញចេញដោយបំពាន គឺជាបាតុភូតមួយផ្សេងក្រោមច្បាប់អន្តរជាតិ ហើយជារឿយៗតែងតែជាប់ទាក់ទងទៅនឹងការខ្វះសុវត្ថិភាពក្នុងការកាន់កាប់តាមផ្លូវច្បាប់ ដែលជាធាតុផ្សំមួយដ៏សំខាន់នៃសិទ្ធិមានលំនៅដ្ឋានសមរម្យ។ ការបណ្តេញចេញដោយបំពានមានចំណែកផ្តល់ផលវិបាកជាច្រើន ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងផលវិបាកបណ្តាលមកពីការឲ្យចាកចេញតាមទំនើងចិត្ត[ii] រួមទាំងការបញ្ជូនប្រជាជន ការបណ្តេញមហាជន ការចាកចេញទៅទាំងហ្វូង ការបោសសំអាតជាតិពន្ធុ និងការអនុវត្តន៍ផ្សេងទៀតពាក់ព័ន្ធ នឹងការចាកចេញដោយបង្ខំចិត្ត ឬដោយមិនស្ម័គ្រចិត្តនៃប្រជាជន ពីផ្ទះសម្បែង ដីធ្លីនិងសហាគមន៍របស់ខ្លួន។

៦. ការបណ្តេញចេញដោយបំពាន គឺជាការរំលោភបំពានដ៏ធ្ងន់ធ្ងរលើសិទ្ធិមនុស្សជាច្រើន ដែលបានទទួលស្គាល់ជាអន្តរជាតិ រួមមានសិទ្ធិមានផ្ទះសម្បែង អាហារ ទឹក សុខភាព ការអប់រំ ការងារ សន្តិសុខបុគ្គល សន្តិសុខលំនៅដ្ឋាន សេរីភាពចាកផុតពីការប្រព្រឹត្តឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប និងសេរីភាព ខាងការដើរហើរ ។ ការបណ្តេញចេញត្រូវតែធ្វើឡើងស្របច្បាប់ ឬធ្វើតែក្នុងករណីលើកលែងប៉ុណ្ណោះ ហើយត្រូវស្របទាំងស្រុងទៅនឹងបញ្ញត្តិពាក់ព័ន្ធនៃច្បាប់សិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិ ។

៧. ការបណ្តេញចេញដោយបំពាន ជំរុញកាន់តែខ្លាំងឡើងថែមទៀតនូវភាពមិនស្មើគ្នា ទំនាស់ក្នុងសង្គម វិយោគកម្ម និង " ការដាក់ឲ្យនៅដាច់ពីគេ" និងដែលប៉ះពាល់ជានិច្ចដល់ប្រជាជនក្រីក្របំផុត ផ្នែកនៃ

---

ii-ស្របតាមគោលការណ៍ ៦ នៃគោលការណ៍ណែនាំស្តីពីការភៀសសឹក ។

សង្គម ដែលងាយរងផលប៉ះពាល់បំផុតខាងសង្គម និងសេដ្ឋកិច្ច និងដែលគេមិនសូវគិតគូរ ជាពិសេស ស្ត្រី កុមារ ជនភាគតិច និងជនជាតិដើមភាគតិច។

៨. ក្នុងបរិបទនៃគោលការណ៍ណែនាំនេះ ការបណ្តេញចេញផ្អែកលើការអភិវឌ្ឍន៍ រួមទាំងការបណ្តេញចេញឯទៀត ដែលជារឿយៗបានគ្រោង ឬបានធ្វើឡើងក្រោមការអះអាងថា ធ្វើដើម្បី "ប្រយោជន៍សាធារណៈ" ដូចជា ការបណ្តេញចេញដែលភ្ជាប់ទៅនឹងការអភិវឌ្ឍន៍ និងគំរោងហេដ្ឋារចនាសម្ព័ន្ធ (រួមទាំងទំនប់វារីអគ្គីសនីធំៗ គំរោងថាមពល ឬឧស្សាហកម្មដែលមានទ្រង់ទ្រាយធំ ឬឧស្សាហកម្មរុករករ៉ែ ឬធនធានផ្សេងទៀត) វិធានការលទ្ធកម្មដីធ្លីដែលជាប់ទាក់ទងនឹងការរៀបចំទីក្រុងជាថ្មី ការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ ការជួសជុលកែលំអលំនៅដ្ឋាន ការកែលំអសោភ័ណ្ឌភាពទីក្រុង ឬកម្មវិធីប្រើប្រាស់ដីធ្លីផ្សេងទៀត (រួមទាំងដើម្បីគោលបំណងកសិកម្ម) ទ្រព្យអចលនទ្រព្យ និងជំលោះដីធ្លី ការវិនិយោគដីធ្លីគ្មានការគ្រប់គ្រងត្រឹមត្រូវ ជំនួញធំៗមានលក្ខណៈជាអន្តរជាតិ ឬព្រឹត្តិការណ៍កីឡា និងដែលសំដែងក្នុងគោលបំណងបរិស្ថាន។ សកម្មភាពទាំងនេះ ក៏រួមផងដែរនូវសកម្មភាពទាំងឡាយដែលគាំទ្រដោយជំនួយ អភិវឌ្ឍន៍អន្តរជាតិ។

៩. ការចាកចេញដោយបង្ខំចិត្ត កើតឡើងដោយសារការបំផ្លាញ ឬការធ្វើឲ្យខូចបរិស្ថាន ការបណ្តេញចេញ ឬការជន្លៀស ដែលមកពីការរំខានជាសាធារណៈ គ្រោះធម្មជាតិ ឬគ្រោះមហន្តរាយដែលមនុស្សជាអ្នកបង្កឡើង ភាពតានតឹង ឬកោលាហល ជម្លោះផ្ទៃក្នុង ឬ

ជម្លោះអន្តរជាតិ ឬជម្លោះចម្រុះ (មានលក្ខណៈជាតិ និង អន្តរជាតិ) និង ភាពបន្ទាន់ជាសាធារណៈ អំពើហឹង្សាក្នុងគ្រួសារ និងការអនុវត្តន៍មួយចំនួនជាប្រពៃណី និងវប្បធម៌ ដែលជារឿយៗកើតឡើងដោយមិនគោរពតាមបទដ្ឋានសិទ្ធិមនុស្ស និងបទដ្ឋានមនុស្សធម៌ ដែលមានស្រាប់ រួមទាំងសិទ្ធិមានលំនៅដ្ឋានសមរម្យ។ ទោះជាយ៉ាងណាក៏ដោយ ស្ថានការណ៍នេះអាចជាប់ទាក់ទងនឹងការពិចារណាថែមទៀតថា គោលការណ៍ណែនាំនេះ មិនដោះស្រាយជាក់លាក់ក្តី ក៏វាអាចផ្តល់ការណែនាំមួយ មានប្រយោជន៍ក្នុងបរិបទនោះ។ សូមទាញចំណាប់អារម្មណ៍លើគោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបានការដោះស្រាយ និងការជួសជុលសំណងការខូចខាតដល់ជនរងគ្រោះ ដោយការរំលោភលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ឬការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ គោលការណ៍ណែនាំស្តីពីការភៀសសឹក និងគោលការណ៍ស្តីពីការដោះស្រាយមានប្រសិទ្ធភាពចំពោះលំនៅដ្ឋាន និងទ្រព្យសម្បត្តិសំរាប់ជនភៀសខ្លួន និងជនភៀសសឹក។

១០. ទន្ទឹមនឹងការទទួលស្គាល់អំពីបរិបទដែលកើតមានការបណ្តេញចេញ គោលការណ៍ណែនាំនេះ ផ្តោតលើការផ្តល់ការណែនាំដល់រដ្ឋនានាអំពីវិធានការ និងនីតិវិធីដែលត្រូវបានអនុម័ត ដើម្បីធានាថាការបណ្តេញចេញផ្អែកលើការអភិវឌ្ឍន៍ មិនត្រូវបានធ្វើផ្ទុយទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលមានស្រាប់ឡើយ ហើយដូច្នេះវាមិនបង្កើតឲ្យមាន " ការបណ្តេញចេញដោយបំពាន " ឡើយ ។ គោលការណ៍ណែនាំនេះ មានគោលបំណងផ្តល់នូវឧបករណ៍មួយ

ដាក់ស្តែងដើម្បីជួយរដ្ឋ និងទីភ្នាក់ងារនានាក្នុងការបង្កើតគោលនយោបាយ ច្បាប់នីតិវិធី និងវិធានការបង្ការ ដើម្បីធានាថាការបណ្តេញចេញនឹងមិនកើតមាន និងដើម្បីផ្តល់នូវការដោះស្រាយមានប្រសិទ្ធភាពចំពោះអ្នកដែលត្រូវគេរំលោភបំពានសិទ្ធិរបស់ខ្លួន ក្នុងករណីមិនមានការបង្ការ ។

## II. កាតព្វកិច្ចទូទៅ

### ក. អ្នកមានភារកិច្ច និងចរិតនៃកាតព្វកិច្ច

១១. ទន្ទឹមនឹងមានតួអង្គផ្សេងៗអាចនឹងធ្វើទណ្ឌកម្ម ការទាមទារ ការស្នើ ការផ្តួចផ្តើមគំនិត ការអភ័យទោស ការយល់ព្រមឲ្យមានការបណ្តេញចេញដោយបំពានក្តី រដ្ឋមានកាតព្វកិច្ចត្រូវអនុវត្តបទដ្ឋានសិទ្ធិមនុស្ស និងបទដ្ឋានមនុស្សធម៌ ដើម្បីធានាឲ្យមានការគោរពសិទ្ធិទាំងឡាយដែលមានចែងក្នុងសន្ធិសញ្ញា និងគោលការណ៍ទូទៅស្តីពីច្បាប់អន្តរជាតិសាធារណៈ ដូចមានចែងក្នុងគោលការណ៍ណែនាំនេះ។ ទោះជាយ៉ាងណាក៏ដោយ គោលការណ៍ណែនាំនេះមិនអាចឲ្យភាគីនានា រួមទាំង បុគ្គល និងអ្នកគ្រប់គ្រងគំរោង ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងស្ថាប័ន ឬអង្គការឯទៀត សាជីវកម្មឆ្លងប្រទេស និងសាជីវកម្មផ្សេងទៀត និងភាគីឯកត្តជន រាប់ទាំងម្ចាស់ផ្ទះ និងម្ចាស់ដី រួចផុតពីរាល់ការទទួលខុសត្រូវឡើយ។

១២. ក្រោមច្បាប់អន្តរជាតិ កាតព្វកិច្ចរបស់រដ្ឋ រួមមានការគោរព ការការពារ និងការបំពេញសិទ្ធិមនុស្សទាំងអស់ និងសេរីភាពជាមូល

ដ្ឋាន ។ នេះមានន័យថា រដ្ឋត្រូវ ៖ ទប់មិនឲ្យមានការរំលោភសិទ្ធិមនុស្សក្នុងស្រុក និងក្រៅប្រទេសរបស់ខ្លួន ធានាថា ភាគីឯទៀតដែលស្ថិតក្នុងដែនសមត្ថកិច្ច និងការគ្រប់គ្រងមានប្រសិទ្ធភាពមិនត្រូវរំលោភសិទ្ធិអ្នកដទៃឡើយ ហើយត្រូវចាត់វិធានការបង្ការ និងកែខៃ ដើម្បីលើកកំពស់សិទ្ធិមនុស្ស និងផ្តល់ការជួយឧបត្ថម្ភដល់បុគ្គលទាំងឡាយណាដែលត្រូវគេរំលោភសិទ្ធិ។ កាតព្វកិច្ចទាំងនេះត្រូវអនុវត្តបន្តនិងទន្ទឹមពេលគ្នា ហើយមិនចាំបាច់ត្រូវចាត់វិធានការតាមឋានានុក្រមឡើយ។

## ខ. គោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន

១៣. តាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជនគ្រប់រូប មានសិទ្ធិមានលំនៅដ្ឋានសមរម្យ ជាផ្នែកមួយនៃសិទ្ធិមានកំរិតជីវភាពរស់នៅគ្រប់គ្រាន់។ សិទ្ធិមានលំនៅដ្ឋានសមរម្យ រួមមាន ក្នុងចំណោមសិទ្ធិដទៃទៀត គឺសិទ្ធិទទួលបានការការពារប្រឆាំងនឹងការជ្រៀតជ្រែកតាមទំនើងចិត្ត ឬដោយខុសច្បាប់ លើសិទ្ធិឯកជន គ្រួសារ ផ្ទះសំបែង និងសុវត្ថិភាពក្នុងការកាន់កាប់ស្របច្បាប់។

១៤. តាមច្បាប់អន្តរជាតិ រដ្ឋត្រូវធានាថា ការការពារប្រឆាំងនឹងការបណ្តេញចេញដោយបំពាន និងសិទ្ធិមនុស្សមានលំនៅដ្ឋានសមរម្យ និងសុវត្ថិភាពក្នុងការកាន់កាប់ ត្រូវបានធានាការពារដោយគ្មានការរើសអើង ទោះជាតាមបែបណាក៏ដោយផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ភាសា សាសនា ឬជំនឿ និន្នាការ នយោបាយ ឬមតិយោបល់

ឯទៀត សញ្ជាតិ ជាតិពន្ធុ ឬដើមកំណើតសង្គម ឋានៈផ្លូវច្បាប់ ឬសង្គម អាយុ ពិការភាព ទ្រព្យសម្បត្តិ កំណើត ឬឋានៈផ្សេងទៀត។

១៥. រដ្ឋត្រូវធានាសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ដើម្បីការពារមិនឲ្យមានការបណ្តេញចេញដោយបំពាន និងការទទួលបានស្មើគ្នានូវសិទ្ធិមានលំនៅដ្ឋានសមរម្យ និងសុវត្ថិភាពក្នុងការកាន់កាប់ ដូចមានចែងក្នុងគោលការណ៍ណែនាំនេះ។

១៦. គ្រប់បុគ្គល ក្រុម និងសហគមន៍ដែលមានសិទ្ធិត្រូវតាំងលំនៅថ្មីដែលរួមមានសិទ្ធិជ្រើសរើសដីធ្លីដែលមានគុណភាពស្មើគ្នា ឬប្រសើរជាង ហើយលំនៅដ្ឋានដែលត្រូវដោះដូរ ត្រូវតែបំពេញលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ ៖ ការចូលទៅដល់ភាពអាចលៃលកបាន អាចរស់នៅបាន សុវត្ថិភាពក្នុងការកាន់កាប់ ភាពគ្រប់គ្រាន់ ខាងវប្បធម៌ ភាពសមស្របនៃទីតាំង និងការប្រើប្រាស់សេវាសំខាន់ៗដូចជាសេវាសុខភាព និងសេវាអប់រំ iii។

១៧. រដ្ឋត្រូវតែធានាឲ្យមានការដោះស្រាយគ្រប់គ្រាន់និងមានប្រសិទ្ធភាពតាមផ្លូវច្បាប់ ឬការដោះស្រាយផ្សេងទៀតដែលត្រឹមត្រូវ និងមានប្រសិទ្ធភាពដល់បុគ្គលណាមួយដែលអះអាងថា គាត់ត្រូវគេរំលោភបំពាន ឬស្ថិតក្នុងការគំរាមកំហែងបំពារបំពានសិទ្ធិរបស់ខ្លួនក្នុងការការពារប្រឆាំងនឹងការបណ្តេញចេញដោយ បំពាន ។

១៨. រដ្ឋត្រូវទប់ស្កាត់ការណែនាំឲ្យប្រើវិធានការសកម្មមុនពាក់ព័ន្ធ

iii-សូមមើលសេចក្តីពន្យល់រួម លេខ៤ ស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ ដែលអនុម័តដោយគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្នុងឆ្នាំ១៩៩១ ។

នឹងការការពារតាមនីតិន័យ (de jure) ឬ តាមព្រឹត្តិន័យ (de facto) ប្រឆាំងនឹងការបណ្ដេញចេញដោយបំពាន។

១៩. រដ្ឋ ត្រូវទទួលស្គាល់ថាការហាមប្រាមការបណ្ដេញចេញដោយបំពាន រួមទាំងការឲ្យចាកចេញតាមទំនើងចិត្ត ដែលនាំឲ្យមានការដូរផ្លាស់ជាតិពន្ធុ សាសនា ឬសមាសភាពពូជសាសន៍របស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់។

២០. រដ្ឋ ត្រូវបង្កើត និងអនុវត្តគោលនយោបាយ និងសកម្មភាពអន្តរជាតិរបស់ខ្លួន ស្របតាមកាតព្វកិច្ចសិទ្ធិ មនុស្ស រួមទាំងតាមរយៈការបន្ត និងការផ្ដល់ជំនួយអភិវឌ្ឍន៍អន្តរជាតិ។

## គ. ការអនុវត្តន៍កាតព្វកិច្ចរដ្ឋ

២១. រដ្ឋ ត្រូវធានាថា ការបណ្ដេញចេញធ្វើបានតែក្នុងករណីលើកលែងប៉ុណ្ណោះ។ ការបណ្ដេញចេញត្រូវបញ្ជាក់មូលហេតុពេញលេញអំពីផលប៉ះពាល់របស់វា ទៅលើសំណុំសិទ្ធិដែលបានទទួលស្គាល់ជាអន្តរជាតិ។ ការបណ្ដេញចេញត្រូវតែ (ក) បានអនុញ្ញាតដោយច្បាប់ (ខ) អនុវត្តស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ (គ) ធ្វើសំរាប់តែគោលបំណងលើកកំពស់សុខមាលភាពទូទៅ[iv] (ឃ) សមហេតុផល និងសមាមាត្រ (ង) ធ្វើ និយតកម្មដើម្បីធានាការផ្ដល់សំណង និងការ

iv-ក្នុងគោលការណ៍ណែនាំនេះ ការលើកស្ទួយសុខមាលភាពទូទៅ សំដៅដល់វិធានការដែលរដ្ឋ បានចាត់ឡើងស្របតាមកាតព្វកិច្ច សិទ្ធិមនុស្ស អន្តរជាតិរបស់ខ្លួន ជាពិសេស សេចក្ដីត្រូវការក្នុងការធានាសិទ្ធិមនុស្សរបស់បុគ្គលងាយរងគ្រោះបំផុត។

ស្តារនីតិសម្បទាសមរម្យ និងទាំងស្រុង និង (ច) អនុវត្តស្របតាមគោលការណ៍ណែនាំនេះ។ ការការពារដែលបានផ្តល់ដោយសេចក្តីតម្រូវខាងនីតិវិធីទាំងនេះ អនុវត្ត ចំពោះជនដែលងាយរងគ្រោះ និងក្រុមមនុស្សដែលរងផលប៉ះពាល់ ដោយមិនគិតថាពួកគេមាន ឬគ្មានប័ណ្ណកម្មសិទ្ធិផ្ទះសំបែង និងទ្រព្យសម្បត្តិ តាមច្បាប់ជាតិនោះទេ ។

២២. រដ្ឋ ត្រូវអនុម័តវិធានការច្បាប់ និងគោលនយោបាយហាមប្រាមការបណ្តេញចេញទាំងឡាយណា ដែលធ្វើឡើង មិនស្របទៅនឹងកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។ រដ្ឋ គួរទប់ស្កាត់ឲ្យបានជាអតិបរមាការទាមទារ ឬ ការដកហូតផ្ទះសម្បែង ឬដីធ្លី ហើយជាពិសេស នៅពេលដែលសកម្មភាពនេះ មិនរួមចំណែកដល់ការទទួលបានសិទ្ធិមនុស្ស។ ឧទាហរណ៍ ការបណ្តេញចេញ អាចចាត់ថាមានហេតុផលត្រឹមត្រូវ ប្រសិនជាវិធានការស្តី ពីកំណែទម្រង់ ឬការបែងចែកដីធ្លីជាថ្មី មានពាក់ព័ន្ធជាពិសេស ដល់ផលប្រយោជន៍បុគ្គល ក្រុម ឬ សហគមន៍ដែលងាយរងគ្រោះ ឬដែលត្រូវបានគេដកហូតសិទ្ធិ។ រដ្ឋ គួរអនុវត្តទោសបញ្ញត្តិព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីទៅលើ បុគ្គល អង្គភាពឯកជន ឬអង្គភាពសាធារណៈណាមួយ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដែលធ្វើការបណ្តេញចេញ ក្នុងលក្ខណៈមួយមិនស្របទាំងស្រុងទៅនឹងច្បាប់ជាតិដែលកំពុងអនុវត្ត និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ រដ្ឋ ត្រូវធានាឲ្យមានការដោះស្រាយតាមផ្លូវច្បាប់គ្រប់គ្រាន់ និងមានប្រសិទ្ធភាព ឬការដោះស្រាយសមស្របផ្សេងទៀតចំពោះបុគ្គលទាំងឡាយដែលរងផលប៉ះពាល់ ដែលងាយរងគ្រោះ ឬការពារមិនឲ្យមានការបណ្តេញចេញដោយបំពាន។

២៣. រដ្ឋ ត្រូវចាត់វិធានការតាមធនធានដែលខ្លួនមានជាអតិបរមា ដើម្បីធានាឲ្យមនុស្សគ្រប់រូបអាស្រ័យផលស្មើគ្នា នូវសិទ្ធិមានលំនៅដ្ឋានសមរម្យ។ រដ្ឋ មានកាតព្វកិច្ចអនុម័តវិធានការច្បាប់ និងគោលនយោបាយសមស្រប ដើម្បីធានាការពារបុគ្គល ក្រុម និងសហគមន៍ពីការបណ្តេញចេញដោយបំពាន ដែលមិនស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលមានស្រាប់ឲ្យបានឆាប់រហ័ស v ។

២៤. ដើម្បីធានាថា មិនមានទម្រង់ណាមួយនៃការរើសអើងផ្លូវច្បាប់ ឬផ្លូវផ្សេងទៀត ប៉ះពាល់អវិជ្ជមានលើការអាស្រ័យផលសិទ្ធិមានផ្ទះសម្បែងសមរម្យ រដ្ឋ គួរពិនិត្យទូទៅឡើងវិញអំពីច្បាប់ និងគោលនយោបាយជាតិដែលពាក់ព័ន្ធ ក្នុងទិសដៅធានាឲ្យច្បាប់ និងគោលនយោបាយទាំងនោះស្របតាមបញ្ញត្តិសិទ្ធិមនុស្សអន្តរជាតិ។ ការពិនិត្យទូទៅឡើងវិញនេះ គួរធានាផងដែរថាច្បាប់ បទបញ្ញា និងគោលនយោបាយដែលមាន ស្រាប់និយាយអំពីឯកជនភាវូបនីយកម្មនៃសេវាសាធារណៈ ការទទួលកេរ្តិ៍មរតក និងការអនុវត្តន៍ជាវប្បធម៌ ដើម្បីកុំឲ្យឈានទៅរក ឬ សម្រួលឲ្យមានការបណ្តេញចេញដោយបំពានvi ។

២៥. ដើម្បីធានាកំរិតអតិបរមានៃការការពារផ្លូវច្បាប់ឲ្យមានប្រសិទ្ធភាពប្រឆាំងនឹងការបណ្តេញចេញដោយបំពាន សំរាប់មនុស្សគ្រប់រូប

v-សូមមើលសេចក្តីពន្យល់រួម លេខ៣ ស្តីពីចរិតលក្ខណៈនៃកាតព្វកិច្ចរបស់រដ្ឋភាគី ដែលអនុម័តក្នុងឆ្នាំ ១៩៩០ ដោយគណៈកម្មាធិការ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

vi-សូមមើលគោលការណ៍ណែនាំស្តីពីលំនៅដ្ឋាននិងការប្រកាន់ពូជសាសន៍នៅក្នុងរបាយការណ៍អ្នករាយការណ៍ពិសេសគណៈគម្មាការទទួលបន្ទុកសិទ្ធិមនុស្សស្តីពីការមានលំនៅដ្ឋានសមរម្យ និងសិទ្ធិមានលំនៅដ្ឋានសមរម្យ

ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន រដ្ឋ គួរតែចាត់វិធានការជាបន្ទាន់ ក្នុងគោលបំណងផ្តល់សិទ្ធិកាន់កាប់ស្របច្បាប់ដល់បុគ្គល គ្រួសារ និងសហគមន៍ទាំងឡាយណាដែលបច្ចុប្បន្ន មិនទាន់មានការការពារដូចនេះ រួមទាំងបុគ្គលទាំងឡាយគ្មានប័ណ្ណកម្មសិទ្ធិផ្លូវការលើផ្ទះសម្បែង និងដីធ្លី។

២៦. រដ្ឋ ត្រូវធានាសិទ្ធិអាស្រ័យផលស្មើគ្នានូវផ្ទះសម្បែងគ្រប់គ្រាន់សំរាប់បុរស និងស្ត្រី។ ការនេះតម្រូវឲ្យរដ្ឋ អនុម័ត និងអនុវត្តវិធានការពិសេស ដើម្បីការពារស្ត្រីពីការបណ្តេញចេញដោយបំពាន។ វិធានការទាំងនេះ គួរធានាឲ្យមានការផ្តល់ប័ណ្ណកម្មសិទ្ធិផ្លូវការលើផ្ទះសម្បែង និងដីធ្លីឲ្យស្ត្រីគ្រប់រូប។

២៧. រដ្ឋ គួរតែធានាថា បទដ្ឋានសិទ្ធិមនុស្សជាធរមាន ត្រូវបានធ្វើសមាហរណកម្មទៅក្នុងទំនាក់ទំនងអន្តរជាតិរបស់ខ្លួន រួមទាំងតាមរយៈជំនួយអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទុន និងការចូលរួមក្នុងវេទិកា និងអង្គការពហុភាគី។ រដ្ឋ គួរតែអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន ចំពោះសហប្រតិបត្តិការអន្តរជាតិ[vii] ទោះក្នុងនាមជាប្រទេសអ្នកផ្តល់ជំនួយ ឬជាអ្នកទទួលផល(អត្ថគាហក)ក្តី។ រដ្ឋ គួរធានាថា អង្គការអន្តរជាតិនានា ដែលខ្លួនគឺជាតំណាង ត្រូវទប់ការផ្តល់ ឬការអនុវត្តន៍គំរោង កម្មវិធី ឬគោលនយោបាយណាមួយដែលពាក់ព័ន្ធការបណ្តេញចេញដោយបំពាន ចំពោះការបណ្តេញចេញ

vii-ដូចមានចែងក្នុងមាត្រា ២២ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ៥៥ និងមាត្រា ៥៦ នៃធម្មនុញ្ញសហប្រជាជាតិ មាត្រា ២ កថាខ័ណ្ឌ ១, ១១, ១៥, ២២ និងមាត្រា ២៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មាត្រា ២៣ កថាខ័ណ្ឌ ៤ មាត្រា ២៨ កថាខ័ណ្ឌ ៣ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

ណាមួយ ដែលមិនស្របទាំងស្រុងនឹងច្បាប់អន្តរជាតិ និងការគូស
បញ្ជាក់ក្នុងគោលការណ៍ណែនាំនេះ ។

## ឃ. យុទ្ធសាស្ត្រ គោលនយោបាយ និងកម្មវិធីបង្ការ

២៨. រដ្ឋ គួរតែអនុម័ត តាមធនធានដែលខ្លួនមានជាអតិបរមា យុទ្ធ
សាស្ត្រ គោលនយោបាយ និងកម្មវិធីសមស្រប ដើម្បីធានាការការ
ពារប្រកបដោយប្រសិទ្ធភាពដល់បុគ្គល ក្រុម និងសហគមន៍ ប្រឆាំង
ការបណ្ដេញ ចេញដោយបំពាន និងផលវិបាករបស់វា។

២៩. រដ្ឋ គួរតែពិនិត្យឡើងវិញឲ្យបានទូលំទូលាយអំពីយុទ្ធសាស្ត្រ
គោលនយោបាយ និងកម្មវិធីពាក់ព័ន្ធ ក្នុង គោលដៅធានាភាពស្រប
គ្នារបស់វាទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ ក្នុងបរិបទនេះ ការ
ពិនិត្យឡើងវិញនេះ ត្រូវតែខិតខំដកចេញនូវបទបញ្ញត្តិទាំងឡាយ
ដែលរក្សាទុក ឬធ្វើឲ្យភាពមិនស្មើគ្នាដែលមានស្រាប់ ហើយរិតតែ
មានខ្លាំងឡើងថែមទៀត ដែលធ្វើឲ្យប៉ះពាល់អវិជ្ជមានទៅលើស្ត្រី
និងក្រុមមនុស្សដែលងាយរងគ្រោះ និងដែលគេមិនសូវគិតគូរ។
រដ្ឋាភិបាល ត្រូវចាត់វិធានការពិសេស ដើម្បីធានាថាគោលនយោ-
បាយ និងកម្មវិធីផ្សេងៗមិនត្រូវបានបង្កើត ឬអនុវត្តន៍ដោយរើសអើង
និងបោះបង់ចោលមិនគិតគូរដល់បុគ្គលទាំងឡាយ ដែលក្រីក្រនៅទី
ក្រុង ឬនៅតំបន់ជនបទឡើយ។

៣០. រដ្ឋ គួរតែចាត់វិធានការបង្ការមួយចំនួន ដើម្បីបញ្ចៀស និង/ឬ

បំបាត់ហេតុផលដែលបានគូសបញ្ជាក់ អំពីការបណ្តេញចេញដោយបំពាន ដូចជាការរកកម្រៃលើដីធ្លី និងអចលនវត្ថុ។ រដ្ឋ គួរតែពិនិត្យឡើងវិញអំពីប្រតិបត្តិការ និងការធ្វើនិយតកម្មទីផ្សារផ្ទះសម្បែង និងការជួល ហើយប្រសិនជាចាំបាច់ ត្រូវធ្វើអន្តរាគមន៍ ដើម្បីធានាថាកំលាំងទីផ្សារមិនបង្កើនភាពងាយរងគ្រោះដល់អ្នកមានប្រាក់ចំណូលទាប និងក្រុមបុគ្គលដែលមិនសូវបានគេគិតគូរ មិនត្រូវបានគេបណ្តេញចេញដោយបំពានឡើយ។ ក្នុងករណីតម្លៃដីធ្លី និងផ្ទះសម្បែងឡើងខ្ពស់ រដ្ឋ គួរធានាការពារគ្រប់គ្រាន់ប្រឆាំងនឹងការគាបសង្កត់លើរូបកាយ ឬសេដ្ឋកិច្ច លើអ្នកស្រុក ដោយបង្ខំឲ្យចាកចេញ ឬដកហូតសិទ្ធិមានផ្ទះសម្បែង និងដីធ្លីសមរម្យពីពួកគាត់។

៣១. អាទិភាពក្នុងការផ្តល់ដីធ្លី និងផ្ទះសម្បែង គួរតែធានាឲ្យដល់ក្រុមប្រជាជនក្រីក្រ ដូចជា មនុស្សចាស់- ជរា កុមារ និងជនពិការ។

៣២. រដ្ឋ ត្រូវផ្តល់អាទិភាពក្នុងការស្វែងរកយុទ្ធសាស្ត្រផ្សេងៗ ដើម្បីកាត់បន្ថយជាអប្បបរមាការចាកចេញដោយបង្ខំចិត្ត។ ការវាយតំលៃទាំងស្រុង និងទូលំទូលាយអំពីផលប៉ះពាល់ គួរតែធ្វើមុនពេលចាប់ផ្តើមអនុវត្តគំរោងអ្វីមួយ ដែលអាចនឹងនាំឲ្យមានការបណ្តេញចេញ និងការចាកចេញដោយបង្ខំចិត្ត ដោយផ្អែកលើការអភិវឌ្ឍន៍ក្នុងទិសដៅធានាទាំងស្រុងនូវសិទ្ធិមនុស្សរបស់បុគ្គល ក្រុម និងសហគមន៍ទាំងអស់ដែលនឹងត្រូវរងផលប៉ះពាល់ រួមទាំងការការពារពួកគេពីការបណ្តេញចេញដោយបំពាន។ ការវាយតម្លៃអំពី "ផលប៉ះពាល់ដោយការបណ្តេញចេញ" គួរបញ្ចូលផងដែរ នូវការស្វែងរកជម្រើស និងយុទ្ធសាស្ត្រផ្សេងៗ ដើម្បីកាត់បន្ថយជាអប្បបរមានូវគ្រោះថ្នាក់។

៣៣. ការវាយតំលៃអំពីផលប៉ះពាល់ ត្រូវតែគិតគូរពីផលប៉ះពាល់ផ្សេងៗគ្នាពីការបណ្ដេញចេញទៅលើស្ត្រី កុមារ មនុស្សចាស់ជរា និងផ្នែកនៃសង្គម ដែលគេមិនសូវគិតគូរ។ ការវាយតំលៃទាំងនេះ គួរតែផ្អែកលើការប្រមូលទិន្នន័យវិភាគ ដូចជា គ្រប់ផលប៉ះពាល់ផ្សេងៗអាចត្រូវបានកំណត់ និងដោះស្រាយយ៉ាងត្រឹមត្រូវ ។

៣៤. ការបណ្ដុះបណ្ដាលគ្រប់គ្រាន់ក្នុងការអនុវត្តន៍បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ គួរតែបានតម្រូវឲ្យមាន និង ផ្ដល់ដល់អ្នកវិជ្ជាជីវៈពាក់ព័ន្ធ រួមទាំង មេធាវី មន្ត្រីអនុវត្តច្បាប់ អ្នកធ្វើផែនការក្រុង និងតំបន់ និងបុគ្គលិកឯទៀត ដែលចូលរួមក្នុងការរៀបចំធ្វើគំរោង ការគ្រប់គ្រង និងការអនុវត្តន៍គំរោងអភិវឌ្ឍន៍។ ការនេះ ត្រូវបញ្ចូលការបណ្ដុះបណ្ដាលអំពីសិទ្ធិស្ត្រី ដោយសង្កត់ធ្ងន់អំពីកង្វល់ និងតម្រូវការពិសេសរបស់ស្ត្រីទាក់ទង នឹងបញ្ហាផ្ទះសម្បែង និងដីធ្លី។

៣៥. រដ្ឋ គួរធានាការផ្សព្វផ្សាយព័ត៌មានគ្រប់គ្រាន់ អំពីគោលនយោបាយ ច្បាប់ និងសិទ្ធិមនុស្ស ទាក់ទងនឹងការការពារប្រឆាំងនឹងការបណ្ដេញចេញដោយបំពាន។ រដ្ឋ គួរផ្ដោតការយកចិត្តទុកជាពិសេសដល់ការផ្សព្វផ្សាយព័ត៌មានសមស្រប និងទាន់ពេលវេលាដល់ក្រុមផ្សេងៗ ជាពិសេសដល់ប្រជាជនដែលងាយរងផលប៉ះពាល់ដោយការបណ្ដេញចេញ តាមរយៈវិធីសាស្ត្រ និងបណ្ដាញ វប្បធម៌សមស្រប។

៣៦. រដ្ឋ ត្រូវធានាថាបុគ្គល ក្រុម និងសហគមន៍ ត្រូវបានគេការពារពីការបណ្ដេញចេញ នៅក្នុងពេលមួយ ដែលករណីជាក់ស្ដែងរបស់

ពួកគេ កំពុងស្ថិតក្នុងការពិនិត្យពិចារណានៅចំពោះមុខស្ថានប័ន ច្បាប់ជាតិ តំបន់ និងអន្តរជាតិ។

## III. មុននឹងធ្វើការបណ្តេញចេញ

៣៧. ការធ្វើផែនការក្រុង ឬជនបទ និងដំណើរការអភិវឌ្ឍន៍ ត្រូវតែមានការចូលរួមពីបុគ្គលទាំងអស់ ដែលត្រូវរងផលប៉ះពាល់ ហើយគួរបញ្ចូលសមាសធាតុដូចតទៅ ៖ (ក) ជូនដំណឹងជាមុន ក្នុងរយៈពេលសមស្រប ដល់បុគ្គលទាំងឡាយដែលនឹងត្រូវរងផលប៉ះពាល់ថា ការបណ្តេញចេញកំពុងតែពិចារណា ហើយថាគេនឹងរៀបចំឲ្យមានការផ្តល់ព័ត៌មានជាសាធារណៈអំពីគំរោង និងជម្រើសដែលបានស្នើឡើង (ខ) ការផ្សព្វផ្សាយអោយមានប្រសិទ្ធភាពដោយអាជ្ញាធរផ្សេងៗ អំពីព័ត៌មានពាក់ព័ន្ធជាមុន រួមទាំងរបាយការណ៍ដីធ្លី និងគំរោងស្នើឡើងអំពីការតាំងលំនៅថ្មី ដែលនិយាយជាពិសេសអំពីការខិតខំប្រឹងប្រែងការពារប្រយោជន៍ក្រុម បុគ្គល ដែលងាយរងគ្រោះ (គ) ផ្តល់រយៈពេលមួយសមស្រប សំរាប់ការពិនិត្យឡើងវិញ ជាសាធារណៈ អំពីសេចក្តីពន្យល់ និង ឬ ការជំទាស់ចំពោះគំរោងដែលបានស្នើឡើង (ឃ) ផ្តល់ឱកាស និងការខិតខំប្រឹងប្រែងសម្រួលផ្នែកច្បាប់ និងបច្ចេកទេស និងការណែនាំផ្សេងទៀត ដល់ប្រជាជនដែលរងផលប៉ះពាល់ អំពីសិទ្ធិ និងជម្រើសរបស់ពួកគេ និង (ង) ការរៀបចំឲ្យមានសវនាការសាធារណៈ ដែលផ្តល់ឲ្យអ្នករងផលប៉ះពាល់ និងមេធាវីរបស់ពួកគេ នូវឪកាសតវ៉ាសេចក្តីសំរេចបណ្តេញចេញ និង ឬ បង្ហាញសំណើជាជំរើសផ្សេងៗ និងការបញ្ជាក់ច្បាស់ពីការទាមទារ

របស់ខ្លួន និងអាទិភាពអភិវឌ្ឍន៍។

៣៨. រដ្ឋ គួរតែរិះរកជម្រើសគ្រប់បែបយ៉ាងជំនួសឲ្យការបណ្តេញចេញ។ ក្រុមបុគ្គលដែលនឹងត្រូវរងផលប៉ះពាល់ រួមមានស្ត្រី ជនជាតិដើមភាគតិច និងជនពិការ ក៏ដូចជាអ្នកដែលធ្វើការក្នុងនាមបុគ្គលដែលរងផលប៉ះពាល់ មានសិទ្ធិទទួលបានព័ត៌មានពាក់ព័ន្ធការចូលរួម និងការពិគ្រោះយោបល់យ៉ាងពេញលេញ លើរាល់កិច្ចដំណើរការទាំងមូល និងដើម្បីស្នើសុំឲ្យមានជម្រើសផ្សេងៗ ដែលអាជ្ញាធរគួរតែពិនិត្យពិចារណាឲ្យបានត្រឹមត្រូវ។ ក្នុងករណីមិនអាចឈានដល់ការព្រមព្រៀងគ្នាលើជម្រើសណាមួយ ដែលបានស្នើឡើងក្នុងចំណោមភាគីទាំងឡាយដែលពាក់ព័ន្ធ ស្ថាប័នឯករាជ្យមួយដែលមានអំណាចធម្មនុញ្ញ ដូចជាតុលាការ សាលាក្តី ឬ ក្រុមអធិការ គួរតែជួយសម្រុះសម្រួលធ្វើជាអាជ្ញាកណ្តាល ឬវិនិច្ឆ័យក្តីតាមការចាំបាច់។

៣៩. ក្នុងពេលដំណើរការធ្វើគំរោង រដ្ឋ ត្រូវផ្តល់ឱកាសសំរាប់ការពិភាក្សា និងការពិគ្រោះយោបល់មានប្រសិទ្ធភាពដល់បុគ្គលគ្រប់រូបដែលរងផលប៉ះពាល់ រួមទាំងស្ត្រី និងក្រុមបុគ្គលដែលងាយរងគ្រោះ និងដែលគេមិនសូវគិតគូរ ហើយប្រសិនជាចាំបាច់ តាមរយៈការអនុម័តនីតិវិធី ឬវិធានការពិសេសផ្សេងៗ។

៤០. មុននឹងសំរេចធ្វើការបណ្តេញចេញណាមួយ អាជ្ញាធរត្រូវបង្ហាញថា ការបណ្តេញចេញនេះ គឺមិនអាចជៀសផុត និងស្របតាមការសន្យាសិទ្ធិមនុស្សអន្តរជាតិ ដែលគិតគូរអំពីសុខមាលភាពទូទៅ។

៤១. សេចក្តីសំរេចណាមួយទាក់ទងនឹងការបណ្តេញចេញ គួរតែបាន

ប្រកាសជាលាយលក្ខអក្សរ ជាភាសាជាតិ ឬ ភាសាក្នុងស្រុកឲ្យបុគ្គលគ្រប់រូបដែលពាក់ព័ន្ធបានដឹងជាមុន។ ការជូនដំណឹងពីការបណ្តេញចេញ គួរតែបញ្ជាក់មូលហេតុលំអិតសំរាប់ការសំរេចចិត្ត ដោយរួមបញ្ចូលទាំង (ក) អវត្តមាននៃជំរើសដែលមានហេតុផលសមស្រប (ខ) សេចក្តីលំអិតទាំងស្រុងនៃជំរើសដែលបានស្នើឡើង និង (គ) ប្រសិនជាគ្មានជំរើសណាមួយទេ រាល់វិធានការទាំងឡាយ និងអ្វីដែលអាចដឹងជាមុន ត្រូវចាត់ឡើងដើម្បីកាត់បន្ថយជាអប្បបរមា នូវផលប៉ះពាល់អវិជ្ជមាននៃការបណ្តេញចេញ។ សេចក្តីសំរេចចុងក្រោយទាំងអស់ គួរត្រូវបានពិនិត្យឡើងវិញតាមផ្លូវច្បាប់ និងតាមផ្លូវរដ្ឋបាល។ ភាគីទាំងឡាយ ត្រូវតែបានធានាក្នុងការផ្តល់មេធាវីទាន់ពេលវេលា ដោយគ្មានការបង់ប្រាក់ ប្រសិនជាចាំបាច់។

៤២. គួររៀបចំឲ្យមានការជូនដំណឹង និងផ្តល់លទ្ធភាពឲ្យអ្នកដែលត្រូវបណ្តេញចេញធ្វើបញ្ជីសារពើភ័ណ្ឌ ដើម្បីវាយតំលៃអំពីទ្រព្យសម្បត្តិរបស់ខ្លួន ការវិនិយោគ និងមុខទំនិញផ្សេងទៀត ដែលអាចត្រូវរងការខូចខាត។ អ្នកដែលរងការបណ្តេញចេញ គួរត្រូវបានផ្តល់ឱកាស ដើម្បីវាយតំលៃ និងចងក្រងការបាត់បង់ដែលមិនមែនជាលុយកាក់ដែលត្រូវផ្តល់ជាសំណង។

៤៣. ការបណ្តេញចេញ មិនគួរនាំឲ្យបុគ្គលទាំងឡាយបាត់បង់ផ្ទះសម្បែង ឬ រងគ្រោះដោយការរំលោភបំពានលើសិទ្ធិផ្សេងៗរបស់មនុស្សឡើយ។ រដ្ឋ ត្រូវធ្វើបញ្ញត្តិមួយសំរាប់ការអនុម័តរាល់វិធានការសមស្របតាម កំរិតធនធានជាអតិបរមារបស់ខ្លួន ដែលមានជាពិសេសចំពោះអ្នកគ្មានលទ្ធភាពផ្ទាល់ខ្លួន ក្នុងការធានាការមានផ្ទះ

សម្បែងផ្សេង ការតាំងទីលំនៅថ្មី ឬការប្រើប្រាស់ដីធ្លីដែលមាន និងដែលបានផ្តល់ឲ្យសំរាប់បង្កបង្កើនផលតាមករណីជាក់ស្តែង។ ផ្ទះសម្បែងថ្មី គួរតែតាំងនៅយ៉ាងជិតបំផុតនឹងកន្លែងស្នាក់នៅពីខាងដើម និងប្រភពនៃការរកស៊ីចិញ្ចឹមជីវិតរបស់អ្នកដែលត្រូវបានបណ្តេញចេញទាំងនោះ។

៤៤. រាល់វិធានការតាំងទីលំនៅថ្មី មានដូចជា ការសាងសង់ផ្ទះសម្បែង ការផ្តល់សេវា ទឹក អគ្គីសនី អនាម័យ សាលារៀន និងការផ្តល់ដីធ្លី និងទីតាំងផ្សេងៗ ត្រូវតែស្របតាមគោលការណ៍ណែនាំនេះ និងគោលការណ៍សិទ្ធិមនុស្ស ដែលបានទទួលស្គាល់ជាអន្តរជាតិ ហើយត្រូវតែធ្វើឲ្យចប់សព្វគ្រប់ មុននឹងឲ្យពួកគាត់រុះរើពីកន្លែងរស់នៅបច្ចុប្បន្នរបស់ខ្លួន ទៅកាន់ទីតាំងថ្មី viii។

## IV. នៅក្នុងពេលបណ្តេញចេញ

៤៥. សេចក្តីតម្រូវខាងនីតិវិធីសំរាប់ធានាការគោរពបទដ្ឋានសិទ្ធិមនុស្ស គឺបញ្ចូលរួមទាំងវត្តមាននៃអាណត្តិ របស់មន្ត្រីរដ្ឋាភិបាល ឬតំណាងរបស់ពួកគាត់នៅទីនោះ ក្នុងអំឡុងពេលនៃការបណ្តេញចេញ។ មន្ត្រីរដ្ឋាភិបាល តំណាងរបស់ពួកគាត់ និងអ្នកអនុវត្តការបណ្តេញចេញ ត្រូវបង្ហាញលិខិតសំគាល់ខ្លួនដល់អ្នកដែលប្រឈមនឹងការបណ្តេញចេញ និងបង្ហាញលិខិតអនុញ្ញាតផ្លូវការសំរាប់អនុវត្ត

viii-សូមមើលផ្នែកទី៥ នៃគោលការណ៍ណែនាំនេះ ។

ការបណ្តេញចេញនេះ ។

៤៦. អ្នកសង្កេតការអព្យាក្រឹត្យ រួមទាំង អ្នកសង្កេតការថ្នាក់តំបន់ និង អន្តរជាតិ គួរតែត្រូវបានអនុញ្ញាតឲ្យចូលទៅទីនោះ តាមការស្នើសុំ ដើម្បីធានាតម្លាភាព និងការអនុវត្តន៍ស្របតាមគោលការណ៍សិទ្ធិមនុស្សអន្តរជាតិ នៅក្នុងពេលអនុវត្តការបណ្តេញចេញណាមួយ។

៤៧. ការបណ្តេញចេញ មិនត្រូវអនុវត្តក្នុងលក្ខណៈមួយដែលរំលោភលើសេចក្តីថ្លៃថ្នូរ និងសិទ្ធិរស់រានមានជីវិត និងសន្តិសុខនៃជនទាំងឡាយដែលរងផលប៉ះពាល់ឡើយ។ រដ្ឋ ត្រូវចាត់វិធានការផងដែរ ដើម្បីធានាថា ស្ត្រីមិនស្ថិតក្នុងកម្មវត្ថុនៃអំពើហឹង្សា និងការរើសអើងផ្អែកលើភេទក្នុងពេលបណ្តេញចេញ ហើយធានាថាសិទ្ធិកុមារត្រូវតែបានការពារ។

៤៨. ការប្រើប្រាស់កំលាំងណាមួយស្របច្បាប់ ត្រូវតែគោរពតាមគោលការណ៍ស្តីពីភាពចាំបាច់ និងភាពសមាមាត្រ ក៏ដូចជាគោលការណ៍ជាមូលដ្ឋានស្តីពីការប្រើប្រាស់កំលាំង និងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ និងក្រមសីលធម៌ជាតិ ឬ ក្នុងស្រុក ស្របតាមការប្រតិបត្តិច្បាប់អន្តរជាតិ និងបទដ្ឋានសិទ្ធិមនុស្ស។

៤៩. ការបណ្តេញចេញ មិនត្រូវធ្វើនៅពេលធាតុអាកាសមិនល្អ ពេលយប់ នៅក្នុងពេលបុណ្យជាតិ ឬ បុណ្យសាសនា នៅមុនការបោះឆ្នោត ឬ នៅក្នុងពេល ឬ នៅមុនពេលប្រឡងនៅសាលារៀនឡើយ។

៥០. រដ្ឋ និងភ្នាក់ងាររបស់ខ្លួន ត្រូវចាត់វិធានការ ដើម្បីធានាថាគ្មាន

នរណាម្នាក់ ត្រូវស្ថិតក្នុងកម្មវត្ថុនៃការវាយប្រហារដោយផ្ទាល់ ឬដោយមិនរើសមុខ ឬ អំពើហឹង្សាផ្សេងទៀត ជាពិសេសប្រឆាំងនឹងស្ត្រី និងកុមារ ឬ ដកហូតតាមទំនើងចិត្តនូវទ្រព្យសម្បត្តិ ឬ កម្មសិទ្ធិដោយសារតែការកំទេចចោល អគ្គីភ័យ និងទម្រង់ផ្សេងទៀតនៃការបំផ្លិចបំផ្លាញដោយគិតទុកជាមុន ការធ្វេសប្រហែស ឬ ទម្រង់ណាមួយនៃការធ្វើទណ្ឌកម្ម ជាសមូហភាព។ ទ្រព្យសម្បត្តិ និងកម្មសិទ្ធិដែលបានបន្សល់ទុកដោយអចេតនា គួរត្រូវបានការពារប្រឆាំងនឹងការបំផ្លិចបំផ្លាញ និងការយកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ការកាន់កាប់ ឬការប្រើប្រាស់ដោយខុសច្បាប់ និងតាមទំនើងចិត្ត។

៥១. អាជ្ញាធរ និងភ្នាក់ងាររបស់ខ្លួន មិនគួរតម្រូវ ឬ បង្ខំបុគ្គលដែលត្រូវគេបណ្តេញចេញ ឲ្យវាយកំទេចផ្ទះសម្បែងរបស់ខ្លួន ឬ គ្រោងសំណង់ផ្សេងទៀតឡើយ។ គេត្រូវទុកឲ្យបុគ្គលដែលរងផលប៉ះពាល់សំរេចចិត្តដោយខ្លួនក្នុងការងារនេះ ហើយការធ្វើដូច្នេះ ក៏អាចជួយសម្រួលឲ្យគាត់រក្សាបាននូវទ្រព្យរបស់ និងសម្ភារៈសំណង់មួយចំនួនផងដែរ។

## V. បន្ទាប់ពីការបណ្តេញចេញ : ជំនួយបន្ទាន់ និងការតាំងទីលំនៅថ្មី

៥២. រដ្ឋាភិបាល និងភាគីណាមួយផ្សេងទៀត ដែលទទួលខុសត្រូវផ្តល់សំណងសមរម្យ និងការស្រុះស្រួលសមស្របផ្សេងទៀត ឬ ការធ្វើឲ្យដូចដើមវិញប្រសិនជាអាចធ្វើបាន ត្រូវតែធ្វើឲ្យបានយ៉ាងឆាប់បំផុតក្រោយពីការបណ្តេញចេញ លើកលែងតែការឲ្យចាកចេញក្នុង

ករណីប្រធានសក្តិ។ ក្នុងកំរិតអប្បបរិមាដោយមិនគិតពីកាលៈទេសៈ និងដោយគ្មានការរើសអើង អាជ្ញាធរមានសមត្ថកិច្ច ត្រូវធានាថា បុគ្គល ឬ ក្រុមដែលត្រូវគេបណ្តេញចេញ ជាពិសេសអ្នកដែលគ្មានលទ្ធភាពដោយផ្ទាល់ខ្លួន មានសិទ្ធិទទួលបានជាប់លាប់ និងមានសុវត្ថិភាពនូវ (ក) អាហារចាំបាច់ ទឹកស្អាត និងអនាម័យ (ខ) ជំរក និងផ្ទះសម្បែងជាមូលដ្ឋាន (គ) សំលៀកបំពាក់សមស្រប (ឃ) សេវាវេជ្ជសាស្ត្រចាំបាច់ (ង) ប្រភពសំរាប់ចិញ្ចឹមជីវិត (ច)ចំណីសត្វ និងការប្រើប្រាស់ប្រភពទ្រព្យសម្បត្តិរួម ដែលពួកគេបានពឹងអាស្រ័យនៅពេលកន្លងមក និង (ឆ)ការអប់រំបុត្រធីតា និងកន្លែងគាំពារកុមារ។ រដ្ឋ គួរធានាផងដែរថា សមាជិកខ្សែស្រឡាយគ្រួសារ ឬសហាគមន៍តែមួយជាមួយគ្នា មិនត្រូវបានគេបំបែកឲ្យនៅទីទៃពីគ្នា ដោយសារតែការបណ្តេញចេញឡើយ។

៥៣. កិច្ចខិតខំប្រឹងប្រែងពិសេស គួរត្រូវបានធ្វើឡើង ដើម្បីធានាការចូលរួមដោយស្មើភាពគ្នារបស់ស្ត្រី នៅក្នុងគ្រប់ដំណើរការធ្វើផែនការ និងក្នុងការចែកចាយសេវា និងការផ្គត់ផ្គង់ចាំបាច់ផ្សេងៗ។

៥៤. ដើម្បីធានាការពារសិទ្ធិមនុស្សក្នុងបទដ្ឋានមួយខ្ពស់បំផុតខាងសុខភាពរាងកាយ និងសុខភាពផ្លូវចិត្ត បុគ្គលត្រូវគេបណ្តេញចេញគ្រប់រូបដែលរបួស និងឈឺ ព្រមទាំងជនពិការ គួរតែទទួលបានកិច្ចគាំពារផ្នែកវេជ្ជសាស្ត្រ និងការយកចិត្តទុកដាក់ចាំបាច់ឲ្យបានពេញលេញ និងជាក់ស្តែងបំផុត និងដោយគ្មានការពន្យាពេល គ្មានការបែងចែកដោយសារហេតុផលណាមួយ ដែលមិនទាក់ទងនឹងវេជ្ជសាស្ត្រ។ ប្រសិនជាចាំបាច់ បុគ្គលត្រូវគេបណ្តេញចេញ គួរតែទទួល

បានសេវាសង្គមកិច្ច និងសេវាចិត្តសាស្ត្រ។ គួរតែយកចិត្តទុកដាក់ ជាពិសេសចំពោះ (ក) សេចក្តីត្រូវការខាងសុខភាពស្ត្រី និងកុមារ រាប់ទាំងការអាចរកបានអ្នកផ្តល់សេវាគាំពារសុខភាពស្ត្រី នៅពេលណាដែលចាំបាច់ និងសេវាផ្សេងៗទៀតដូចជាកិច្ចគាំពារសុខភាពបន្តពូជ និងសេវាប្រឹក្សាយោបល់សមស្របសំរាប់ជនរងគ្រោះ ដោយអំពើរំលោភផ្លូវភេទ និងអំពើរំលោភផ្សេងទៀត (ខ) ធានាការបន្តពិនិត្យព្យាបាលផ្នែកវេជ្ជសាស្ត្រ ដោយគ្មានការបង្អាក់ដោយសារតែការបណ្តេញចេញ ឬការតាំងទីលំនៅថ្មី និង (គ) ការបង្ការជម្ងឺឆ្លង និងជម្ងឺឆ្លងរាលដាល រាប់ទាំងមេរោគអេដស៍/ជម្ងឺអេដស៍ នៅកន្លែងតាំងទីលំនៅថ្មី ។

៥៥. ទីតាំងថ្មីដែលបានកំណត់ ត្រូវតែបំពេញតាមលក្ខខណ្ឌស្តីពីលំនៅដ្ឋានសមរម្យ ស្របតាមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ លក្ខខណ្ឌទាំងនេះរួមមាន[xi] (ក) សុវត្ថិភាពក្នុងការកាន់កាប់ (ខ) សេវាសម្ភារៈ អាគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដូចជា ទឹកស្អាតថាមពលសំរាប់ចំអិនអាហារ គ្រឿងឧបករណ៍សំរាប់កំដៅ និងគ្រឿងបំភ្លឺ សម្ភារៈអានាម័យ និងសម្ភារៈសំរាប់លាងសំអាត មធ្យោបាយរក្សាទុកម្ហូបអាហារ សេវាចោលសំរាម ប្រព័ន្ធបង្ហូរទឹកនៅទីតាំងសេវាសង្គ្រោះបន្ទាន់ ធានធានរួម និងធានធានធម្មជាតិ តាមការសមស្រប (គ) ផ្ទះសម្បែងអាចរកទិញបាន (ឃ) ផ្តល់ផ្ទះសម្បែងធំទូលាយសមល្មមសំរាប់អ្នកស្រុករស់នៅ ការពារទប់ទល់នឹងអាកាសធាតុត្រជាក់ សំណើម កំដៅ ភ្លៀង ខ្យល់ ឬ ការគំរាមកំហែងផ្សេង

xi-សូមមើលសេចក្តីពន្យល់រួមលេខ ៤ ស្តីពីលំនៅដ្ឋាន ដែលបានអនុម័តដោយគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្នុងឆ្នាំ១៩៩១

ទៀតដល់សុខភាពភាព អន្តរាយខាងរចនាសម្ព័ន្ធ និងភ្នាក់ងារចម្លង មេរោគ និងធានាសុវត្ថិភាពរាងកាយអ្នកកាន់កាប់ (ង) សេវាដែល ក្រុមប្រជាពលរដ្ឋក្រីក្រ អាចរកបានពេលត្រូវការចាំបាច់ (ច) ការមាន ជំរើសការងារ និងមុខរបរ សេវាគាំពារសុខភាព សាលារៀន មណ្ឌល គាំពារកុមារ និងសេវាសង្គមកិច្ចផ្សេងទៀត ទាំងនៅតំបន់ជនបទ និង នៅទីក្រុង និង (ឆ) លំនៅដ្ឋានសមស្របតាមវប្បធម៌។ ដើម្បីធានា សន្តិសុខខាងលំនៅដ្ឋាន សិទ្ធិមានលំនៅដ្ឋានសមរម្យ គួររាប់បញ្ចូល ផងដែរនូវធាតុសារវន្តមួយចំនួនដូចជា ៖ សិទ្ធិឯកជន និងសន្តិសុខ ការចូលរួមធ្វើការសំរេចចិត្ត សេរីភាពរួចផុតពីអំពើហឹង្សា និងការ ទទួលបានការដោះស្រាយណាមួយត្រឹមត្រូវ និងមានប្រសិទ្ធភាព ចំពោះអំពើរំលោភបំពានណាមួយដែលបានទទួលរង។

៥៦. ក្នុងការកំណត់ភាពស្របគ្នានៃការតាំងទីលំនៅថ្មីទៅនឹងគោល ការណ៍ណែនាំនេះ រដ្ឋ គួរតែធានាថា ក្នុងបរិបទនៃករណីនៃការតាំង ទីលំនៅថ្មីណាមួយ គឺត្រូវតែប្រកាន់ខ្ជាប់នូវលក្ខណៈវិនិច្ឆ័យដូចខាង ក្រោមនេះ ៖

(ក) គ្មានការតាំងទីលំនៅថ្មីណាមួយអាចកើតមានទេ រហូតដល់ពេល ដែលគោលនយោបាយជាក់លាក់មួយ ស្តីពីការតាំងទីលំនៅថ្មី ត្រូវ បានរៀបចំឡើងស្របតាមគោលការណ៍ណែនាំនេះ។

(ខ) ការតាំងទីលំនៅថ្មី ត្រូវតែធានាថា សិទ្ធិស្ត្រី សិទ្ធិកុមារ សិទ្ធិជន ជាតិដើមភាគតិច និងសិទ្ធិរបស់ក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះ ត្រូវបានការពារដោយស្មើភាពគ្នា រួមទាំងសិទ្ធិកម្មសិទ្ធិរបស់ពួកគាត់

លើទ្រព្យសម្បត្តិ និងសិទ្ធិប្រើប្រាស់ធនធានផ្សេងៗ។

(គ) អ្នកស្នើឲ្យអនុវត្ត និង ឬ អ្នកអនុវត្តការតាំងទីលំនៅថ្មី ត្រូវតែបានតម្រូវដោយច្បាប់ ឲ្យចេញចំណាយទាំងឡាយណាដែលពាក់ព័ន្ធនឹងការងារនេះ រាប់ទាំងការចំណាយគ្រប់បែបយ៉ាងលើការតាំងទីលំនៅថ្មី។

(ឃ) គ្មានបុគ្គល ក្រុម ឬ សហគមន៍រងផលប៉ះពាល់ណាមួយ ត្រូវខូចផលប្រយោជន៍នោះទេ បើនិយាយពីសិទ្ធិមនុស្សរបស់គាត់ ហើយសិទ្ធិរបស់ពួកគាត់ក្នុងការបន្តលើកកំពស់ស្ថានភាពរស់នៅ ក៏មិនស្ថិតក្រោមការបំពានដែរ។ បញ្ហានេះ ត្រូវអនុវត្តដោយស្មើភាពគ្នារវាងសហគមន៍ម្ចាស់ផ្ទះដែលស្ថិតនៅកន្លែងតាំងទីលំនៅថ្មី និងបុគ្គល ក្រុម និងសហគមន៍ទាំងឡាយដែលប្រឈមនឹងការបណ្តេញចេញដោយបំពាន។

(ង) ត្រូវធានាថា សិទ្ធិបុគ្គល ក្រុម ឬ សហគមន៍រងផលប៉ះពាល់មានសិទ្ធិបានដឹង និងបានយល់ព្រមទាំងស្រុងជាមុនអំពីការតាំងទីលំនៅថ្មី។ រដ្ឋ ត្រូវផ្តល់ភាពគាប់ចិត្តគ្រប់បែបយ៉ាងដែលចាំបាច់ សេវា និងឱកាសសេដ្ឋកិច្ចនៅទីតាំងដែលបានស្នើឡើង។

(ច) ពេលវេលា និងការចំណាយថវិកាចាំបាច់សំរាប់ការធ្វើដំណើរទៅនិងមកកន្លែងធ្វើការ ឬ ការទទួលបាន សេវាសារវ័ន្តផ្សេងៗ មិនត្រូវឲ្យគ្រួសារដែលមានប្រាក់ចំណូលទាប ចំណាយប្រាក់កាសច្រើនហួសហេតុលើសេវាទាំងនេះឡើយ។

(ឆ) កន្លែងតាំងទីលំនៅថ្មី មិនត្រូវស្ថិតនៅលើដីភក់ជ្រាំកខ្វក់ ឬ នៅជិតគៀកនឹងប្រភពភក់ជ្រាំកខ្វក់ ដែលគំរាមកំហែងដល់សិទ្ធិទទួលបានបទដ្ឋានខ្ពស់បំផុតនៃសុខភាពរាងកាយ និងផ្លូវចិត្តរបស់អ្នកស្រុកឡើយ។

(ជ) ត្រូវផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់បុគ្គល ក្រុម ឬ សហគមន៍រងផលប៉ះពាល់ និងសហគមន៍ឯទៀត អំពីរាល់គំរោងរបស់រដ្ឋ និងដំណើរការធ្វើផែនការ និងការអនុវត្តន៍ផ្សេងៗទាក់ទងនឹងកន្លែងដែលត្រូវតាំងទីលំនៅថ្មី រួមទាំងព័ត៌មានដែលអះអាងអំពីការប្រើប្រាស់កន្លែង ឬ ទីតាំងត្រូវបណ្តេញចេញ និងអ្នកទទួលផលប្រយោជន៍ពីទីតាំងនោះ។ ត្រូវគិតគូជាពិសេស ដើម្បីធានាថាជនជាតិដើមភាគតិចជនជាតិភាគតិច អ្នកគ្មានដីធ្លី ស្ត្រី និងកុមារមានអ្នកតំណាង និងបានរាប់បញ្ចូលក្នុងកិច្ចដំណើរការនេះ។

(ឈ) ដំណើរការទាំងមូលនៃការតាំងទីលំនៅថ្មី ត្រូវតែបានអនុវត្តដោយមានការចូលរួមទាំងស្រុងពី និងជាមួយ បុគ្គល ក្រុម ឬ សហគមន៍ដែលរងផលប៉ះពាល់។ ជាពិសេស រដ្ឋ គួរតែគិតគូរអំពីរាល់គំរោងផ្សេងទៀត ដែលបុគ្គល ក្រុម ឬ សហគមន៍រងផលប៉ះពាល់បានស្នើឡើង។

(ញ) ប្រសិនជា បន្ទាប់ពីមានសវនាការសាធារណៈមួយត្រឹមត្រូវ និងពេញលេញហើយៗបានរកឃើញថា នៅតែមានសេចក្តីត្រូវការបន្តធ្វើការតាំងលំនៅថ្មី ដូច្នេះបុគ្គល ក្រុម ឬ សហគមន៍ដែលរងផលប៉ះពាល់ត្រូវតែបានជូនដំណឹងជាមុនរយៈពេលយ៉ាងតិច ៩០ថ្ងៃ មុន

កាលបរិច្ឆេទការតាំងទីលំនៅថ្មីហើយ ។

(ដ) មន្ត្រីរដ្ឋាភិបាលមូលដ្ឋាន និងអ្នកសង្កេតការអព្យាក្រឹត ដែលមានការអនុញ្ញាតត្រឹមត្រូវ ត្រូវតែមានវត្តមាន ក្នុងពេលធ្វើការតាំងទីលំនៅថ្មី ដើម្បីធានាមិនឲ្យមានការប្រើប្រាស់កំលាំង អំពើហឹង្សា ឬ ការបំភិតបំភ័យ។

៥៧. គោលនយោបាយស្តារនីតិសម្បទា ត្រូវបញ្ចូលកម្មវិធីនានាដែលបានគាក់តែងឡើងសំរាប់ស្ត្រី និងក្រុម បុគ្គលដែលងាយរងគ្រោះ និងក្រុមបុគ្គលដែលគេមិនសូវគិតគូរ ដើម្បីធានាឲ្យពួកគេទទួលបានស្មើភាពគ្នានូវសិទ្ធិខាងផ្ទះសម្បែង ម្ហូបអាហារ ទឹក សុខ-ភាព ការអប់រំ ការងារ សន្តិសុខបុគ្គល សន្តិសុខផ្ទះសម្បែង សេរីភាពរួចផុតពីការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកកិត្តិយស និងសេរីភាពក្នុងការដើរហើរ។

៥៨. បុគ្គល ក្រុម ឬ សហគមន៍ដែលរងផលប៉ះពាល់ដោយការបណ្តេញចេញ មិនគួរទទួលរងការខូចប្រយោជន៍ដល់សិទ្ធិរបស់ខ្លួនឡើយ រាប់ទាំងសិទ្ធិរបស់ពួកគាត់ក្នុងការសំរេចបានជាបណ្តើរៗនូវសិទ្ធិមានលំនៅដ្ឋានសមរម្យ។ សិទ្ធិនេះ ត្រូវអនុវត្តស្មើភាពគ្នានឹងសហគមន៍ម្ចាស់ផ្ទះនៅកន្លែងតាំងទីលំនៅថ្មី។

## VI. ការដោះស្រាយត្រឹមត្រូវ សំរាប់ការបណ្តេញចេញដោយបំពាន

៥៩. បុគ្គលគ្រប់រូបដែលត្រូវគេគំរាមកំហែង ឬ ស្ថិតក្នុងកម្មវត្ថុនៃការ

បណ្តេញចេញដោយបំពាន មានសិទ្ធិទទួលបានការដោះស្រាយត្រឹមត្រូវមានប្រសិទ្ធភាព និងទាន់ពេលវេលា។ ការដោះស្រាយមួយសមស្រប រួមមានសវនាការត្រឹមត្រូវ មានមេធាវីការពារ មានជំនួយច្បាប់ ការប្រគល់ឲ្យម្ចាស់ដើមវិញ ការធ្វើឲ្យដូចដើមវិញ ការដោះស្រាយឡើងវិញ ការស្តារនីតិសម្បទា និងការជួសជុលសំណាង ហើយប្រសិនជាអាច គួរតែអនុវត្តតាមគោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបានការដោះស្រាយ និងការជួសជុលសំណាងការខូចខាតដល់ជនរងគ្រោះដោយការរំលោភដ៏កម្រោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ឬ ការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ។

## ក. ការផ្តល់សំណង

៦០. ប្រសិនជាការបណ្តេញចេញ មិនអាចចៀសផុត និងចាំបាច់សំរាប់ការលើកកំពស់សុខមាលភាពទូទៅ រដ្ឋ ត្រូវផ្តល់ ឬ ធានាឲ្យមានការផ្តល់សំណងត្រឹមត្រូវ និងយុត្តិធម៌សំរាប់ការបាត់បង់ចលនទ្រព្យ អចលទ្រព្យ ឬ របស់របរផ្សេងទៀត រួមទាំងសិទ្ធិ ឬ ផលកម្រៃក្នុងទ្រព្យនោះ។ សំណង គួរតែបានផ្តល់ចំពោះការខូចខាត ដែលបានវាយតំលៃខាងសេដ្ឋកិច្ច តាមការសមស្រប និងសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃការរំលោភបំពាន និងកាលៈទេសៈនៃករណីនីមួយៗ ដូចជា ការបាត់បង់ជីវិត ឬ អវយវៈដៃជើង ការធ្វើឲ្យអន្តរាយដល់រាងកាយ និងស្មារតី ការបាត់បង់ឱកាសផ្សេងៗ រួមទាំងឱកាសការងារ និង មុខរបរ ការអប់រំ និងអត្ថប្រយោជន៍សង្គម ការខូតខាតសម្ភារៈ ការបាត់បង់ប្រាក់ចំណូល រួមទាំងការបាត់បង់សក្តានុពលនៃប្រាក់

ចំណូល ការខូចសីលធម៌ និងការចំណាយសំរាប់ជំនួយច្បាប់ ឬ អ្នកជំនាញ ថ្នាំពេទ្យ និងសេវាពេទ្យ សេវាចិត្តសាស្ត្រ និងសេវាសង្គម។ ទោះជាក្នុងករណីណាក៏ដោយ សំណងជាប្រាក់ មិនត្រូវជំនួសសំណងជាអចលនទ្រព្យ ក្នុងរូបភាពជាដីធ្លី និងធនធានទ្រព្យរួមឡើយ។ ប្រសិនជាមានការដកហូតយកដីធ្លីអ្នកដែលត្រូវគេបណ្តេញចេញ គួរតែទទួលសំណងជាដីធ្លីដែលមានគុណភាព ទំហំ និងតំលៃស្មើគ្នា ឬ តំលៃខ្ពស់ជាង។

៦១. ប្រជាពលរដ្ឋទាំងអស់ដែលត្រូវគេបណ្តេញចេញ មិនគិតថាគេមាន ឬ គ្មានប័ណ្ណកម្មសិទ្ធិដីធ្លីនោះទេ ត្រូវមានសិទ្ធិទទួលបានសំណងការបាត់បង់ ការជួយស្រោចស្រង់ និងការដឹកជញ្ជូនទ្រព្យសម្បត្តិដែលរងផលប៉ះពាល់របស់ខ្លួន រួមទាំងកន្លែងរស់នៅពីខាងដើម និងដីធ្លីដែលបាត់បង់ ឬ ខូចខាតក្នុងដំណើរការនៃការបណ្តេញចេញនេះ។ ដោយពិនិត្យពិចារណាលើកាលៈទេសៈនៃករណីនីមួយៗ ត្រូវអនុញ្ញាតឲ្យមានការផ្តល់សំណង ការបាត់បង់ពាក់ព័ន្ធនឹងទ្រព្យសម្បត្តិក្រៅផ្លូវការ ដូចជាការតាំងលំនៅក្នុងតំបន់ក្រីក្រតាមទីប្រជុំជន។

៦២. បុរស និងស្ត្រី ត្រូវតែជាសហអត្ថគាហក (សហអ្នកទទួលផល) នៃកញ្ចប់សំណងទាំងអស់។ ស្ត្រីដែលនៅលីវ (គ្មានប្តី) និងស្ត្រីមេម៉ាយ ត្រូវមានសិទ្ធិទទួលបានសំណងរបស់ខ្លួនផ្ទាល់។

៦៣. ក្នុងកំរិតមួយដែលមិនស្ថិតក្នុងខ័ណ្ឌនៃជំនួយ សំរាប់ការតាំងទីលំនៅថ្មី ការវាយតំលៃអំពីការខូតខាត សេដ្ឋកិច្ច គួរតែពិចារណាអំពី

ការបាត់បង់ និងការចំណាយផ្សេងៗ ឧទាហរណ៍ អំពីដីឡូត៍ និង រចនាសម្ព័ន្ធផ្ទះសម្បែង ហេដ្ឋារចនាសម្ព័ន្ធ ការដាក់បញ្ចាំអចលនវត្ថុ ឬពិន័យលើបំណុលដទៃទៀត លំនៅដ្ឋានបណ្ដោះអាសន្ន កំរៃសេវាច្បាប់ និងការិយាធិបតេយ្យ លំនៅដ្ឋានជាថ្នូរ ការបាត់បង់ប្រាក់ឈ្នួល និងប្រាក់ចំណូល ការបាត់បង់ឱកាសអប់រំ កិច្ចគាំពារសុខភាព ការតាំងទីលំនៅថ្មី និងថ្លៃដឹកជញ្ជូន (ជាពិសេស ក្នុងករណីនៃការតាំងទីលំនៅថ្មីដែលនៅឆ្ងាយពីប្រភពនៃការចិញ្ចឹមជីវិត)។ ប្រសិនជាផ្ទះសម្បែង និងដីធ្លីផ្ដល់ប្រភពមួយសំរាប់ការចិញ្ចឹមជីវិតដល់អ្នកស្រុកដែលត្រូវគេបណ្ដេញចេញនោះ គឺការវាយតំលៃអំពីផលប៉ះពាល់និងការបាត់បង់ ត្រូវគិតគូរផងដែរអំពីតំលៃនៃការបាត់បង់ការងារ គ្រឿងសម្ភារៈបរិក្ខារ ក្នុងបញ្ជីសារពើពន្ធ សត្វពាហនៈ ដីធ្លី ដើមឈើ ឬដំណាំ និងប្រាក់ឈ្នួល ឬ ប្រាក់ចំណូលដែលថយចុះ ឬ បាត់បង់ ។

## ខ. បដិទាន (ការសងវិញ) និង ការអោយវិលត្រឡប់មកវិញ

៦៥. ករណីនៃការបណ្ដេញចេញដោយបំពាន ដែលពាក់ព័ន្ធនឹងគំរោងការអភិវឌ្ឍន៍ និងហេដ្ឋារចនាសម្ព័ន្ធ (រាប់ទាំងសកម្មភាពទាំងឡាយ ដែលបានរៀបរាប់ក្នុងកថាខ័ណ្ឌទី៨ ខាងលើ) កម្រនឹងមានបដិទាន (ការសងវិញ) និងការអោយវិលត្រឡប់មកវិញណាស់។ ប៉ុន្តែទោះជាដូច្នេះក្តី បើមានករណីនេះកើតឡើង រដ្ឋ គួរតែផ្តល់អាទិភាពដល់សិទ្ធិបុគ្គល ក្រុម និងសហគមន៍ទាំងអស់ ដែលជាកម្មវត្ថុនៃការបណ្តេញចេញដោយបំពាន។ ទោះជាយ៉ាងណាក៏ដោយ គេមិន

ត្រូវបង្ខំបុគ្គល ក្រុម និងសហគមន៍ទាំងនោះ ឲ្យវិលត្រឡប់មកលំនៅដ្ឋាន ដីធ្លី ឬ កន្លែងដើមរបស់ខ្លួនវិញ ផ្ទុយនឹងឆន្ទៈរបស់ជនរងគ្រោះទាំងនោះឡើយ។

៦៥. ប្រសិនជាមានការអោយវិលត្រឡប់មកវិញ ឬការតាំងទីលំនៅថ្មីសមរម្យ ស្របតាមគោលការណ៍ណែនាំទាំងនេះ មិនត្រូវបានផ្តល់ទេ នោះអាជ្ញាធរមានសមត្ថកិច្ច គួរបង្កើតល័ក្ខខណ្ឌ និងផ្តល់មធ្យោបាយផ្សេងៗ រួមទាំងមធ្យោបាយហិរញ្ញវត្ថុ សំរាប់ការស្ម័គ្រចិត្តវិលត្រឡប់ប្រកបដោយសុវត្ថិភាព និងសន្តិសុខ និងសេចក្តីថ្លៃថ្នូរ មកកាន់លំនៅដ្ឋាន ឬ និវេសនដ្ឋានដែលធ្លាប់រស់នៅ។ អាជ្ញាធរទទួលខុសត្រូវ គួរសម្រួលដល់ការធ្វើសមាហរណកម្មអ្នកដែលវិលត្រឡប់មកវិញ និងខិតខំប្រឹងប្រែង ដើម្បីធានាឲ្យមានការចូលរួមពេញទំហឹងពីសំណាក់បុគ្គល ក្រុម និងសហគមន៍នទាំងនោះក្នុងការធ្វើផែនការ និងការរៀបចំដំណើរការនៃការអោយវិលត្រឡប់មកវិញនេះ។ វិធានការពិសេស អាចត្រូវបានចាត់ឡើង ដើម្បីធានាឲ្យស្ត្រីចូលរួមដោយស្មើភាពគ្នា និងមានប្រសិទ្ធភាពក្នុងដំណើរការនៃបដិទាន(ការសងវិញ) និងការវិលត្រឡប់មកវិញ ដើម្បីជំនះបាននូវភាពលំអៀងខាងគ្រួសារ សហគមន៍ ស្ថាប័ន រដ្ឋបាល ច្បាប់ ឬ ភាពលំអៀងឯទៀតខាងយ៉េនឌ័រ ដែលនាំឲ្យមានការប្រកាន់បែងចែក ឬ ការផាត់ចេញនៃស្ត្រីភេទ។

៦៦. អាជ្ញាធរមានសមត្ថកិច្ច មានភារកិច្ច និងការទទួលខុសត្រូវជួយឧបត្ថម្ភដល់បុគ្គល ក្រុម និងសហគមន៍ ដែលវិលត្រឡប់មកវិញ ដើម្បីឲ្យគាត់ទទួលបានវិញ ជាអតិបរមាតាមដែលអាចធ្វើបាន នូវដី

ធ្លី និងរបស់របរផ្សេងៗដែលគាត់បានបន្សល់ទុក ឬ ដែលគេដកហូតពីគាត់ នៅពេលបណ្តេញចេញ។

៦៧. នៅពេលវិលត្រឡប់មកលំនៅដ្ឋាន ឬ និវេសនដ្ឋានរបស់ខ្លួន ហើយមិនអាចទទួលបានវិញនូវដីធ្លី និង របស់របរផ្សេងៗនោះ អាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តល់ឲ្យជនរងគ្រោះពីការបណ្តេញចេញដោយបំពាន ឬ ជួយឧបត្ថម្ភដល់ពួកគាត់ ដើម្បីឲ្យគាត់ទទួលបានសំណងសមស្រប ឬ រូបភាពផ្សេងទៀតនៃការជួសជុលសំណងការខូចខាតប្រកបដោយភាពត្រឹមត្រូវ។

## គ. ការតាំងទីលំនៅថ្មី និងការស្តារនីតិសម្បទា

៦៨. ទន្ទឹមនឹងគ្រប់ភាគីទាំងអស់ ត្រូវផ្តល់អាទិភាពដល់សិទ្ធិនៃការវិលត្រឡប់មកវិញនោះ វាក៏មានករណី មួយចំនួន (រាប់ទាំងការលើកកំពស់សុខមាលភាពទូទៅ ឬ ជាកន្លែងសុវត្ថិភាព សុខភាព ឬ ទទួលបានសិទ្ធិ ទាំងឡាយដែលតម្រូវជាចាំបាច់ ឲ្យមានការតាំងទីលំនៅថ្មីនៃបុគ្គល ក្រុម និងសហគមន៍មួយចំនួន តាមរយៈ ការបណ្តេញចេញផ្អែកលើការអភិវឌ្ឍន៍។ ការតាំងទីលំនៅថ្មី ត្រូវធ្វើតាមលក្ខណៈមួយត្រឹមត្រូវ និងដោយសមធម៌ និងត្រូវស្របទាំងស្រុងទៅនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដូចបានបរិយាយក្នុងផ្នែកទី៥ នៃគោលការណ៍ណែនាំនេះ។

## VII. ការឃ្លាំមើល ការវាយតំលៃ និងការតាមដានការអនុវត្តន៍

៦៩. រដ្ឋភាគីទាំងអស់ គួរឃ្លាំមើលយ៉ាងសកម្ម និងធ្វើការវាយតំលៃ អំពីបរិមាណ និងគុណភាព ដើម្បីកំណត់ចំនួនប្រភេទ និងផលវិបាក រយៈពេលយូរអង្វែងនៃការបណ្តេញចេញ រាប់ទាំងការបណ្តេញចេញ ដោយបំពាន ដែលកើតមានក្នុងដែនដី និងដែនសមត្ថកិច្ចរបស់ខ្លួន។ របាយការណ៍ឃ្លាំមើល និង ការរកឃើញផ្សេងៗ គួរតែផ្សព្វផ្សាយឲ្យ សាធារណៈជន និងភាគីអន្តរជាតិពាក់ព័ន្ធនានា បានដឹង ដើម្បីលើក កំពស់ការអភិវឌ្ឍន៍ នៃទំលាប់អនុវត្តដែលប្រសើរបំផុត និងបទ ពិសោធន៍ក្នុងការដោះស្រាយបញ្ហាផ្សេងៗ ឆ្លងតាមការអនុវត្តន៍កន្លង មក ។

៧០. រដ្ឋភាគីទាំងអស់ គួរប្រគល់ភារកិច្ចឲ្យស្ថាប័នជាតិមួយឯករាជ្យ ដូចជា ស្ថាប័នសិទ្ធិមនុស្សជាតិ ដើម្បីឃ្លាំមើល និងធ្វើការស៊ើបអង្កេត ករណីនៃការបណ្តេញចេញដោយបំពាន និងការអនុវត្តន៍របស់រដ្ឋ តាមគោលការណ៍ណែនាំទាំងនេះ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

## VIII. តួនាទីរបស់សហគមន៍អន្តរជាតិ រួមទាំងអង្គការអន្តរជាតិនានា

៧១. សហគមន៍អន្តរជាតិ មានកាតព្វកិច្ចលើកកំពស់ ការពារ និង បំពេញសិទ្ធិមនុស្សខាងផ្ទះសម្បែង ដីធ្លី និងទ្រព្យសម្បត្តិ។ ស្ថាប័ន ហិរញ្ញវត្ថុ ស្ថាប័នពាណិជ្ជកម្ម ស្ថាប័នអភិវឌ្ឍន៍ និងស្ថាប័ននិងទី ភ្នាក់ងារពាក់ព័ន្ធឯទៀត រួមទាំងរដ្ឋជាសមាជិក ឬ ប្រទេសអ្នកផ្តល់

ជំនួយទាំងអស់ ដែលមានសិទ្ធិបោះឆ្នោតក្នុងស្ថាប័នទាំងនេះ គួរតែគិតគូរយ៉ាងពេញលេញ ដល់ការហាមប្រាមការបណ្តេញចេញដោយបំពាន ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងបទដ្ឋានទាំងឡាយដែលពាក់ព័ន្ធ។

៧២. អង្គការអន្តរជាតិនានា គួរតែបង្កើត ឬ យល់ព្រមទទួលយកយន្តការធ្វើបណ្តឹង សំរាប់ករណីដែលទាក់ទងនឹងការបណ្តេញចេញដោយបំពាន ដែលកើតចេញពីគោលនយោបាយ និងការអនុវត្តន៍របស់ខ្លួនផ្ទាល់។ ការដោះស្រាយតាមផ្លូវច្បាប់មានប្រសិទ្ធភាព គួរតែបានផ្តល់ឲ្យជនរងគ្រោះ ស្របតាមបញ្ញត្តិទាំងឡាយណា ដែលមានចែងក្នុងគោលការណ៍ណែនាំទាំងនេះ។

៧៣. សាជីវកម្មបណ្តោះអាសន្ន និងសហគ្រាសពាណិជ្ជកម្មឯទៀតត្រូវតែគោរពសិទ្ធិមានលំនៅដ្ឋានសមរម្យរបស់មនុស្ស រាប់ទាំងការហាមប្រាមការបណ្តេញចេញដោយបំពាន នៅក្នុងរង្វង់សកម្មភាព និងដែនសមត្ថកិច្ចរបស់ខ្លួនរៀងៗខ្លួន។

## IX. ការបកស្រាយគោលការណ៍

៧៤. គោលការណ៍ណែនាំទាំងនេះ ស្តីពីការបណ្តេញចេញ និងការចាកចេញដោយបង្ខំចិត្ត ផ្អែកលើការអភិវឌ្ឍន៍ មិនត្រូវបានធ្វើការបកស្រាយដោយរិតត្បិត កែប្រែ ឬ ធ្វើឲ្យខូចសិទ្ធិដែលបានទទួលស្គាល់ក្រោមច្បាប់សិទ្ធិមនុស្ស ច្បាប់ជនភៀសខ្លួន ច្បាប់ព្រហ្មទណ្ឌ ឬ

ច្បាប់មនុស្សធម៌អន្តរជាតិ និងបទដ្ឋានពាក់ព័ន្ធ ឬ សិទ្ធិទាំងឡាយស្របតាមច្បាប់ទាំងនេះ និងបទដ្ឋាននានាដែលច្បាប់ជាតិបានទទួលស្គាល់ឡើយ។